ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ




នាយកដ្ឋានអប់រំកុមារតូច
២០២៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១២៤៦ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ១១១៩ អយក.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំ
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ សម្រាប់ជាប្រយោជន៍ក្នុងការអភិវឌ្ឍសាលាមត្តេយ្យសិក្សានៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ .-**

ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ រួមមាន ៖

- ស្តង់ដាទី១ លទ្ធផលសិក្សារបស់សិស្ស
- ស្តង់ដាទី២ ការបង្រៀននិងរៀន



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- ស្តង់ដាទី៣ ការចូលរួមរបស់សហគមន៍
- ស្តង់ដាទី៤ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន
- ស្តង់ដាទី៥ គណនេយ្យភាពរបស់សាលារៀន។

ខ្លឹមសារទាំងស្រុងនៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ ប្រធាននាយកដ្ឋានអប់រំកុមារតូច និងប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៣ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអប់រំកុមារតូច

# បុព្វកថា

ការកសាងបាននូវមូលធនមនុស្ស ភាពជាពលរដ្ឋល្អ និងពលរដ្ឋសកល ចាំបាច់ត្រូវចាប់ផ្តើមតាំងពីដំបូងនៃជីវិត តាមរយៈការអប់រំកុមារតូច។ ការពង្រឹងគុណភាពអប់រំ ត្រូវចាប់ផ្តើមពីកម្រិតមត្តេយ្យសិក្សាឡើងទៅដែលជាមូលដ្ឋានគ្រឹះរឹងមាំត្រៀមខ្លួនជាស្រេចសម្រាប់ការសិក្សានៅកម្រិតបឋមសិក្សា និងមានការអភិវឌ្ឍឈានឡើងជាលំដាប់សម្រាប់ការសិក្សាពេញមួយជីវិត ដើម្បីកសាងធនធានមនុស្សប្រកបដោយសក្តានុពល ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០។

ដើម្បីអភិវឌ្ឍការអប់រំមត្តេយ្យសិក្សាឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឱ្យមានស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ជាមូលដ្ឋានសម្រាប់នាយកសាលា និងគ្រូបង្រៀនមត្តេយ្យសិក្សា ធ្វើស្វ័យវាយតម្លៃ និងពង្រឹងការអនុវត្ត ប្រកបដោយឆន្ទៈម្ចាស់ការ។

ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ជាខ្នាតគំរូមួយសម្រាប់កំណត់វិសាលភាព និងវាស់វែងកម្រិតមត្តេយ្យសិក្សា ក្នុងការធានាបាននូវប្រសិទ្ធភាពនិងគុណភាពអប់រំ ដែលសមស្របតាមស្ថានភាព និងបរិបទរបស់ប្រទេសកម្ពុជា។ ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូរួមមាន ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្សស្តង់ដាទី២៖ ការបង្រៀននិងរៀន ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និងស្តង់ដាទី៥ ៖ គណនេយ្យភាពរបស់សាលារៀន។

ឯកសារនេះ នឹងក្លាយជាឯកសារដ៏មានប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធ ប្រើប្រាស់ជាខ្នាតគំរូក្នុងការអភិវឌ្ឍសាលាមត្តេយ្យសិក្សា។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ថ្នាក់ដឹកនាំ បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានខិតខំអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតីចូលរួមរៀបចំកសាងឯកសារនេះ ឱ្យបានសម្រេចជាផ្លែផ្កាឡើង រួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីកសាងសង្គមកម្ពុជាឱ្យមានវិបុលភាពនិងការអភិវឌ្ឍជានិរន្តរ៍។

ថ្ងៃ សុក្រ ៣កើត ខែមិគសិរ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


**ប្រកាស** ........................................ i

**បុព្វកថា** ........................................ iv

**មាតិកា** ........................................ v

**១- សេចក្តីផ្តើម** ........................................ ១

**២- គោលបំណង** ........................................ ២

**៣- គោលដៅ** ........................................ ៣

**៤. ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ** ........................................ ៣

៤.១ ការរៀបចំស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ........................................ ៣

៤.២ សូចនាករនៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ........................................ ៣

៤.៣ កម្រិតផ្ទៀងផ្ទាត់សូចនាករ ........................................ ៣

៤.៤. ការផ្ទៀងផ្ទាត់លទ្ធផល ........................................ ៣

**៥. សូចនាករស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ** ........................................ ៣

**៦. គោលការណ៍ណែនាំអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ** ........................................ ១៧

**៧. ការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ** ........................................ ៣៣

៧.១. ឧបករណ៍វាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ........................................ ៣៣

៧.២. របបនៃការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ........................................ ៣៣

៧.៣. គំរូនៃការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ........................................ ៣៤

**៨. បែបបទនិងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ** ........................................ ៣៦

៨.១ គោលការណ៍ទូទៅ និងលក្ខណៈវិនិច្ឆ័យ ........................................ ៣៦

៨.២ យន្តការ បែបបទ និងនីតិវិធី ........................................ ៣៦

៨.២.១ សាលាមត្តេយ្យសិក្សា ........................................ ៣៦

៨.២.២ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ........................................ ៣៦

៨.២.៣ មន្ទីរអប់រំ យុវជន និងកីឡា ........................................ ៣៧

៨.២.៤ ក្រសួងអប់រំ យុវជន និងកីឡា ........................................ ៣៨

**៩. សេចក្តីសន្និដ្ឋាន** ........................................ ៣៨

**ឧបសម្ព័ន្ធ** ........................................ ៣៩

**១. សេចក្ដីផ្ដើម**

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តវិធានការកំណែទម្រង់វិស័យអប់រំចាប់តាំងពីឆ្នាំ២០១៤ ជាបួនដំណាក់កាលរួមមានដំណាក់កាលទី១ កំណែទម្រង់ថ្នាក់ជាតិ នៅឆ្នាំ២០១៤, ដំណាក់កាលទី២ កំណែទម្រង់កម្រិតសាលារៀនពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨, ដំណាក់កាលទី៣ កំណែទម្រង់ការកសាងប្រព័ន្ធ និងអភិវឌ្ឍធនធានមនុស្សឈរលើសសរស្តម្ភ៥ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២, និងដំណាក់កាលទី៤ កំណែទម្រង់ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បរិវត្តកម្មសេដ្ឋកិច្ចឌីជីថលចាប់ពីឆ្នាំ២០២២។ ក្នុងន័យសម្រួចវិធានការលើកកម្ពស់គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំតាមរយៈការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន និងការលើកទឹកចិត្តព្រមទាំងបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំគ្រប់លំដាប់ថ្នាក់។ សំដៅសម្រេចឱ្យគោលដៅការអភិវឌ្ឍប្រកបដោយចីរភាពគោលដៅ៤.២ បានកំណត់ថាត្រឹមឆ្នាំ២០៣០ ធានាថាកុមារី និងកុមារាទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែរក្សា ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដូច្នេះពួកគេត្រៀមខ្លួនជាស្រេចសម្រាប់ការអប់រំកម្រិតបឋមសិក្សា។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣ បានកំណត់នៅក្នុងមាត្រា៤៨ រដ្ឋធានារក្សាការពារ សិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាមនិងការការពារ ប្រឆាំងនិងអាជីវកម្មសេដ្ឋកិច្ចនិងកាមគុណលើកុមារ។ និងមាត្រា៧៣ រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង។ ច្បាប់ស្តីពីការអប់រំ មាត្រា១៦ បានកំណត់ថា រដ្ឋត្រូវគាំពារនិងអប់រំកុមារតូចចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សា ដែលជាទូទៅប្រព្រឹត្តនៅទារកដ្ឋាន នៅសហគមន៍ ឬនៅផ្ទះ។ ការអប់រំមត្តេយ្យសិក្សា ត្រូវចាប់អនុវត្តមុនបឋមសិក្សា ដើម្បីត្រៀមលក្ខណៈចូលបឋមសិក្សា។

រាជរដ្ឋាភិបាលបាន និងកំពុងជំរុញការអភិវឌ្ឍសាលារៀនឱ្យមានលក្ខណៈជាសាលាមានបរិស្ថានសមស្របដែលជាមេត្រីរបស់កុមារ។ គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច បានកំណត់ពីវិសាលភាពនៃការគាំពារ និងផ្តល់សេវាអប់រំដល់កុមារតូច ហើយក្នុងនោះក៏បានកំណត់អំពីការផ្តល់សេវាអប់រំតាមរយៈមត្តេយ្យសិក្សាផងដែរ។ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញវិធានការដើម្បីលើកកម្ពស់គុណភាពអប់រំដោយផ្តោតការពង្រឹងគុណភាពសាលារដ្ឋចាប់ពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សា តាមរយៈការពង្រឹងកិច្ចការសំខាន់ៗរួមមាន៖

- ទី១ ការពង្រឹងអភិបាលកិច្ចសាលា
- ទី២ ការពិនិត្យកែសម្រួលនិងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស។
- ទី៣ ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា។
- ទី៤ ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុង

ការអប់រំស្របតាមពាក្យស្លោក "ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ" Public-Community Partnership for Education (PCPE)។

តាមរយៈលទ្ធផលនៃការពិនិត្យតាមដានពាក់កណ្ដាលអាណត្តិ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣។ ក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលគោលនយោបាយចំនួនពីរគឺៈ ១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា និង ២) ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ផ្អែកតាមទស្សនាទានខាងលើក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ តើសាលាមត្តេយ្យសិក្សាជាអ្វី? សាលាមត្តេយ្យសិក្សាជាអង្គភាពសេវាសាធារណៈនៃក្រសួងអប់រំ យុវជន និងកីឡា ដែលស្ថិតនៅជិតប្រជាពលរដ្ឋ ដូចនេះអភិបាលកិច្ចសាលាមត្តេយ្យសិក្សាមានសារៈសំខាន់ណាស់ចំពោះពួកគាត់។ សាលាមត្តេយ្យសិក្សាត្រូវតែអនុវត្តនូវតួនាទី ប្រកបដោយការទទួលខុសត្រូវខ្ពស់លើការបង្រៀន និងរៀន។ តើសាលាមត្តេយ្យសិក្សាបានបំពេញតួនាទីរបស់ខ្លួននិងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋបានប្រសើរហើយឬនៅ? តើសាលាមត្តេយ្យសិក្សាមានសេវាគ្រប់គ្រាន់សម្រាប់កុមាររៀនសូត្រដែរឬទេ? ដូចជាបន្ទប់រៀន បន្ទប់ទឹក ទឹកស្អាត អនាម័យសិក្សា បរិស្ថានល្អក្នុងថ្នាក់ ក្រៅថ្នាក់ បណ្ណាល័យ ទីធ្លាសម្រាប់កុមារលេងគ្រប់ប្រភេទ? តើសេវាទាំងអស់នេះដំណើរការដែរឬទេ? តើសាលាមត្តេយ្យសិក្សាបានរៀបចំឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីអ្នកពាក់ព័ន្ធទាំងអស់ឬនៅ? តើសាលាមត្តេយ្យសិក្សាបានរៀបចំធ្វើសកម្មភាពប្រជុំពិភាក្សា និងពិគ្រោះយោបល់(ការកសាងផែនការសកម្មភាព កម្មវិធីយុទ្ធសាស្ត្រ ឬការធ្វើសេចក្តីសម្រេចរួមគ្នាលើការផ្សព្វផ្សាយផែនការ សារាចររបស់ថ្នាក់ដឹកនាំ ការបិទផ្សាយឯកសារនានា ការបញ្ចូលសារាចរឱ្យបុគ្គលិកម្នាក់ៗជ្រាបបន្តបន្ទាប់គ្នា)? តើធ្វើដូចម្តេចដើម្បីបង្កើនភាពជិតស្និទ្ធជាមួយសហគមន៍ និងផ្តល់ព័ត៌មានទៅសហគមន៍អំពីលទ្ធផលសិក្សារបស់កុមារ។ ចំណុចទាំងអស់ខាងលើ ជាបញ្ហាដែលគណៈគ្រប់គ្រងសាលាមត្តេយ្យសិក្សាត្រូវខិតខំប្រើប្រាស់តួនាទីរបស់ខ្លួនតាមគោលការណ៍អភិបាលកិច្ចល្អ ដើម្បីបម្រើសេវារបស់ប្រជាពលរដ្ឋឱ្យបានល្អ។

ដូច្នេះស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមត្តេយ្យសិក្សា ដោយផ្តោតលទ្ធផលសិក្សារបស់កុមារ ការបង្រៀននិងរៀន ការចូលរួមរបស់សហគមន៍ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន និងគណនេយ្យភាពរបស់សាលារៀន។ ដែលរួមមានស្តង់ដាចំនួន៥ មានសូចនាករគន្លឹះចំនួន២៦ និងសូចនាកររងចំនួន៥៦ សម្រាប់វាស់វែង។

## ២- គោលបំណង

ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ មានគោលបំណងពង្រឹងស្វ័យគ្រប់គ្រងសាលាមត្តេយ្យសិក្សានិងផ្តល់សេវាអប់រំកុមារតូចប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីផ្តល់ឱកាសឱ្យកុមារដែលមានអាយុចាប់ពី៣(បី)ឆ្នាំដល់ក្រោម៦(ប្រាំមួយ)ឆ្នាំ ទទួលបានសេវាអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្ន។

## ៣. គោលដៅ

ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូមានគោលដៅ៖

- ពង្រឹងសមត្ថភាពដល់គណៈគ្រប់គ្រងសាលាមត្តេយ្យសិក្សាលើការងារគ្រប់គ្រងនិងដឹកនាំ និងគ្រប់អ្នកពាក់ព័ន្ធឱ្យយល់ដឹងអំពីការងារដែលមត្តេយ្យសិក្សាត្រូវធ្វើដើម្បីពង្រឹងប្រសិទ្ធភាពការបង្រៀននិងរៀន និងកែលម្អគុណភាពនៃការសិក្សារបស់កុមារ
- វាស់វែងពីកម្រិតប្រសិទ្ធភាពនៃការងារ និងគុណភាពអប់រំកុមារតូច
- ធានាគុណភាព និងនិរន្តរភាពនៃសាលាមត្តេយ្យសិក្សា។

## ៤. ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

### ៤.១ ការរៀបចំស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

ការរៀបចំស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ដើម្បីឆ្លើយតបនឹងកំណែទម្រង់ការគ្រប់គ្រងសាលារៀន ស្របតាមការសម្រួចអាទិភាពនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាសម្រាប់ឆ្នាំ២០២៣-២០២៨ ឱ្យមានគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព។ ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូចំនួន៥ ដូចខាងក្រោម៖

- ស្តង់ដាទី១ លទ្ធផលសិក្សារបស់សិស្ស
- ស្តង់ដាទី២ ការបង្រៀននិងរៀន
- ស្តង់ដាទី៣ ការចូលរួមរបស់សហគមន៍
- ស្តង់ដាទី៤ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន
- ស្តង់ដាទី៥ គណនេយ្យភាពរបស់សាលារៀន។

### ៤.២ សូចនាករនៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

ក្នុងការវាស់វែងស្តង់ដាទាំង៥ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់សូចនាករគន្លឹះចំនួន ២៦ និងសូចនាកររងចំនួន៥៦ ដែលក្នុងនោះ ស្តង់ដាទី១ មានសូចនាករគន្លឹះ៥ និងសូចនាកររងចំនួន១០ ស្តង់ដាទី២ មានសូចនាករគន្លឹះ៩ និងសូចនាកររងចំនួន ១៩ ស្តង់ដាទី៣ មានសូចនាករគន្លឹះ៣ និងសូចនាកររងចំនួន៤ ស្តង់ដាទី៤ មានសូចនាករគន្លឹះ៦ និងសូចនាកររងចំនួន១៩ ស្តង់ដាទី៥ មានសូចនាករគន្លឹះ៣ និងសូចនាកររងចំនួន៤។

### ៤.៣ កម្រិតផ្ទៀងផ្ទាត់សូចនាករ

កម្រិតផ្ទៀងផ្ទាត់សូចនាករ ជាការកំណត់ពីលទ្ធផលតាមបែបគុណវិស័យ ឬបរិមាណវិស័យ ស្របទិដ្ឋភាពជាក់ស្តែងនៃសូចនាករនីមួយៗ ដើម្បីចង្អុលបង្ហាញពីកម្រិតវាស់វែងការអនុវត្តសូចនាករដូចមានបង្ហាញក្នុងតារាងស្តង់ដាសាលាមត្តេយ្យសិក្សាគំរូដូចខាងក្រោម។

### ៤.៤. ការផ្ទៀងផ្ទាត់លទ្ធផល

ការផ្ទៀងផ្ទាត់លទ្ធផល គឺជាការវាយតម្លៃលើការអនុវត្តកម្រិតសូចនាករគន្លឹះចំនួន២៦ និងសូចនាកររងចំនួន៥៦ ដោយដាក់ពិន្ទុផ្អែកលើភស្តុតាងនៃសូចនាករនីមួយៗ ដែលមានពិន្ទុសរុប២៨០ពិន្ទុ ស្មើនឹង១០០%។ សាលាមត្តេយ្យសិក្សាដែលទទួលលទ្ធផលចាប់ពីលក្ខណៈស្តង់ដាឡើងទៅ នឹងត្រូវមានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។ ការផ្ទៀងផ្ទាត់លទ្ធផលត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

- សាលាមត្តេយ្យសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី៩៥% ឡើងទៅ និងត្រូវចាត់ទុកថា មានស្តង់ដាពេញលេញ
- សាលាមត្តេយ្យសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី៨៥% ដល់តិចជាង៩៥% នឹងត្រូវចាត់ទុកថា មានស្តង់ដា
- សាលាមត្តេយ្យសិក្សាអនុវត្តលទ្ធផលសម្រេចបានចាប់ពី ៧៥% ដល់តិចជាង៨៥% និងត្រូវចាត់ទុកថា មានស្តង់ដាអប្បបរមា។

ការផ្ទៀងផ្ទាត់លទ្ធផលត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

**ជំហានទី១** ពិនិត្យផ្ទៀងផ្ទាត់ផ្អែកលើភស្តុតាង ជាកំណត់ត្រាលទ្ធផលជាក់ស្តែងនៃលទ្ធផលតាមសូចនាករវងនីមួយៗ។

**ជំហានទី២** របៀបដាក់ពិន្ទុ ប្រសិនបើភស្តុតាងធៀបទៅនឹងកម្រិតផ្ទៀងផ្ទាត់សូចនាករ បានគ្រប់ចំណុចនិងត្រឹមត្រូវ នោះនឹងទទួលបាន ៥ពិន្ទុ តាមសូចនាករនោះ។

## ៥. សូចនាករស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | |
| ១ | ការប្រមូលកុមារចូលរៀន | | | |
| ១.១ | ភាគរយការប្រមូលកុមារអាយុ ៥ឆ្នាំចូលរៀន មានការកើនឡើង | - ចំនួនកុមារអាយុ ៣, ៤, និង ៥ឆ្នាំ ធៀបនឹងចំនួនកុមារ (ស្ថិតិប្រជាជនអាយុ ៣, ៤, និង៥ ឆ្នាំ)<br>- សាលារៀនមានស្ថិតិកុមារអាយុ ៣, ៤ និង៥ឆ្នាំ ចូលរៀន នៅដើមឆ្នាំសិក្សា (ភូមិចំណុះសាលារៀន)<br>- ផែនទី និងទិន្នន័យខ្នងផ្ទះ<br>- សំបុត្រកំណើត និងសៀវភៅគ្រួសារ<br>- តារាង/បញ្ជីឈ្មោះសិស្សតាមគ្រួសារ (ភូមិចំណុះសាលារៀន | | |
| ១.២ | ភាគរយការប្រមូលកុមារអាយុ ៤ឆ្នាំ ចូលរៀន មានការកើនឡើង | | | |
| ១.៣ | ភាគរយការប្រមូលកុមារអាយុ ៣ឆ្នាំចូលរៀន មានការកើនឡើង | | | |
| ២ | កុមាររៀនបានគង់វង្សនៅក្នុងសាលារៀន | | | |
| ២.១ | ភាគរយកុមារអាយុ ៥ឆ្នាំបានឆ្លងកាត់មត្តេយ្យសិក្សា និងទៅចូលរៀនថ្នាក់ទី១ នៅសាលាបឋមសិក្សា | - ចំនួនសិស្សអាយុ៦ឆ្នាំដែលបានចូលរៀនថ្នាក់ទី១ និងធ្លាប់បានឆ្លងកាត់មត្តេយ្យសិក្សាធៀបនឹងចំនួនសិស្សថ្នាក់ទី១<br>- សាលារៀនមានស្ថិតិកុមារអាយុ ៥ឆ្នាំ | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | **តស្ថុតាង** | **ពិន្ទុ** |
| | | ចូលរៀនថ្នាក់ទី១ សាលាបឋមសិក្សា | | |
| ៣ | **លទ្ធផលនៃការសិក្សារបស់សិស្ស** | | | |
| ៣.១ | ភាគរយកុមារអាយុ៥ឆ្នាំ មានការអភិវឌ្ឍផ្នែកទាំង៥ បានល្អប្រសើរ | - សាលារៀនមានរបាយការណ៍វាយតម្លៃលទ្ធផលនៃការសិក្សាកុមារ ៥ឆ្នាំ ប្រចាំឆ្នាំសិក្សា | | |
| ៤ | **ស្ថានភាពអាហារូបត្ថម្ភរបស់សិស្ស** | | | |
| ៤.១ | ភាគរយកុមារមានស្ថានភាពអាហារូបត្ថម្ភធម្មតា | - បញ្ជីកត់ត្រាស្ថានភាពអាហារូបត្ថម្ភសិស្ស (អាយុ ទម្ងន់ កម្ពស់)<br>- សៀវភៅតាមដានសុខភាពសិស្សម្នាក់ៗ | | |
| ៤.២ | ភាគរយកុមារដែលមានបញ្ហាអាហារូបត្ថម្ភ ទទួលបានកិច្ចអន្តរាគមន៍ | - របាយការណ៍ត្រឡប់ពីមាតាបិតាឬអ្នកអាណាព្យាបាល ក្នុងការសហការជួយអន្តរាគមន៍ឬការនាំកុមារទៅរកសេវាគាំទ្រ<br>- របាយការណ៍ពីកិច្ចអន្តរាគមន៍របស់សេវាសុខាភិបាលមូលដ្ឋាន តាមរយៈគណៈកម្មការសុខភាពសិក្សា តាមសាលារៀន | | |
| ៤.៣ | ភាគរយសិស្សក្រីក្រទទួលបានការឧបត្ថម្ភនានា | - របាយការណ៍ស្ដីពីការផ្ដល់ការឧបត្ថម្ភនានា របស់កម្មវិធីជាតិ ឬកម្មវិធីគាំទ្ររបស់ដៃគូអភិវឌ្ឍ | | |
| ៤.១ | ភាគរយកុមារមានស្ថានភាពអាហារូបត្ថម្ភធម្មតា | - បញ្ជីកត់ត្រាស្ថានភាពអាហារូបត្ថម្ភសិស្ស (អាយុ ទម្ងន់ កម្ពស់)<br>- សៀវភៅតាមដានសុខភាពកុមារម្នាក់ៗ | | |
| ៥ | **សីលធម៌ និងឥរិយាបថរបស់សិស្ស** | | | |
| ៥.១ | ភាគរយកុមារទទួលកិច្ចគាំពារនិងប្រឹក្សាយោលបល់ | - សាលារៀនមានបញ្ជី ព័ត៌មានកត់ត្រាចំនួនកុមាររងហិង្សា(ដូចជាហិង្សាផ្លូវកាយ, ហិង្សាផ្លូវចិត្ត, ហិង្សាផ្លូវភេទ និងការមិនអើពើ) សាលារៀនមានផែនការប្រឹក្សាយោបល់ជាមួយមាតាបិតាអ្នកអាណាព្យាបាល<br>- របាយការណ៍ទទួលបានពីក្រុមបណ្ដាញឪពុកម្ដាយ និងគ.ក.ន.ក.<br>- សាលារៀនមានរបាយការណ៍ និងបញ្ជីវត្តមាន ការប្រឹក្សាយោបល់ជាមួយមាតាបិតា អ្នកអាណាព្យាបាល | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្គាល់ | ពិន្ទុ |
| ៥.២ | សាលារៀនអនុវត្តកម្មវិធីទម្លាប់ល្អ(សីលធម៌ និងឥរិយាបថកុមារ) ជាប្រចាំ | - របាយការណ៍ និងការចុះពិនិត្យវាយតម្លៃជាក់ស្តែង | | |
| ស្តង់ដាទី២៖ ការបង្រៀន និងរៀន | | | | |
| ១ | ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី | | | |
| ១.១ | ភាគរយថ្នាក់រៀនអនុវត្តវិធីសាស្ត្ររៀនតាមរយៈការលេង(Learning Throught Play) | - សាលារៀនមានផែនការសកម្មភាពលេងតាមប្រធានបទ<br>- សាលារៀនមានតារាងរបាយម៉ោងសិក្សាអនុវត្តការលេងដោយសេរី ការលេងដោយមានការណែនាំ និងការលេងល្បែងសិក្សាតាមកម្មវិធីសិក្សាពេញលេញ<br>- សាលារៀនមានបញ្ជីសម្ភារៈល្បែងសិក្សា<br>- សាលារៀនមានសម្ភារៈល្បែងសិក្សារៀបចំតាមជ្រុងថ្នាក់ រៀន<br>- សាលារៀនមានឯកសារសកម្មភាពរបស់កុមារម្នាក់ៗ(Portfolio) | - | |
| ១.២ | ភាគរយថ្នាក់រៀនបានប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀននិងរៀន | - សាលារៀនមានបន្ទប់កុំព្យូទ័រ និងបណ្ណាល័យ<br>- បន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Boad) | | |
| ២ | ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន | | | |
| ២.១ | សាលារៀនបានរៀបចំបំណែងចែកកម្មវិធីសិក្សាតាមកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា | - សាលារៀនមានតារាងបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែ ប្រចាំសប្តាហ៍ និងតាមមុខវិជ្ជា<br>- សាលារៀនមានផែនការបង្រៀនប្រចាំថ្ងៃតាមកាលវិភាគ ប្រចាំសប្តាហ៍ ផែនការបង្រៀន ៣ខែម្តងៗ | | |
| ២.២ | ភាគរយថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា | - សាលារៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមកម្រិតថ្នាក់ និងតាមមុខវិជ្ជា | | |
| ២.៣ | ភាគរយគ្រូបង្រៀនបានធ្វើបច្ចុប្បន្នកម្មកិច្ចតែងការបង្រៀនត្រឹមត្រូវនិងបានអនុវត្តទៀងទាត់ | - គ្រូបង្រៀនបានរៀបចំកិច្ចតែងការបង្រៀនប្រចាំថ្ងៃតាមកម្រិតថ្នាក់ និងចុះទិដ្ឋាការមុននឹងបង្រៀន ដោយនាយកសាលា<br>- សាលារៀនមានស្វ័យវាយតម្លៃលើការ | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | អនុវត្តកិច្ចតែងការបង្រៀន | | |
| ២.៤ | សាលារៀនបានប្រជុំវាយតម្លៃការអនុវត្តកម្មវិធីសិក្សាប្រចាំឆមាស និងប្រចាំឆ្នាំ | - សាលារៀនមានផែនការប្រជុំប្រចាំខែ ឆ្នាំ<br>- សាលារៀនមានរបាយការណ៍ ឬ កំណត់ហេតុប្រជុំ<br>- សាលារៀនមានរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីសិក្សាប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ | | |
| ២.៥ | ភាគរយថ្នាក់រៀនបិទទ្វារ( សរុបថ្នាក់ទាំងអស់គិតជាមធ្យម ) | - របាយការណ៍បូកសរុបបញ្ជីគ្រប់គ្រងវត្តមានរបស់សាលារៀន<br>- បញ្ជីវត្តមានប្រចាំថ្ងៃ<br>- ការបញ្ជាក់ពីប្រភពផ្សេងៗទៀត | | |
| ២.៦ | ចំនួនថ្ងៃសាលារៀនបិទទ្វារដោយមិនមានការអនុញ្ញាត | - សាលារៀនមានកំណត់ហេតុពីការផ្អាកដំណើរការបង្រៀន និងរៀន | | |
| ៣ | សម្ភារៈរៀន និងបង្រៀន | | | |
| ៣.១ | ភាគរយថ្នាក់រៀនមានសម្ភារៈបង្រៀន និងរៀនគ្រប់គ្រាន់តាមកម្មវិធីសិក្សា និងបានឱ្យកុមារមានសម្ភារៈសម្រាប់លេងបានគ្រប់គ្រាន់ | - សាលារៀនមានសម្ភារៈសម្រាប់កុមារលេង តាមកម្មវិធី សិក្សា<br>- សាលារៀន/ថ្នាក់រៀនមានសម្ភារៈផលិតដោយគ្រូ និងកុមារ<br>- សាលារៀនមានបញ្ជីស្រង់ឈ្មោះសម្ភារៈដែលបានផលិត<br>- សាលារៀនមានសម្ភារៈលេងមានចំនួនគ្រប់គ្រាន់សម្រាប់ កុមារយ៉ាងតិច៩៥%<br>- សាលារៀនមានការរៀបចំជ្រុងថ្នាក់រៀនត្រឹមត្រូវតាម ប្រកាសលេខ ១៤៥៤ អយក.ប្រក ចុះថ្ងៃទី១០ សីហា ២០២២<br>- សាលារៀនមានបញ្ជីកត់ត្រាសម្ភារៈ | | |
| ៤ | **ការជួយគាំទ្រសិស្ស** | | | |
| ៤.១ | ភាគរយកុមារបានធ្វើកិច្ចការនៅសាលារៀន និងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀន | - សាលារៀនមានគ្រូកត់ត្រាសកម្មភាពកុមារអនុវត្តប្រចាំថ្ងៃ<br>- សាលារៀនមានសន្លឹកកិច្ចការសម្រាប់កុមារអនុវត្តតាមខ្លឹមសារមេរៀន និងឯកភាពពីមាតាបិតា ឬអ្នកអាណាព្យាបាល | | |
| ៤.២ | ភាគរយកុមារបានធ្វើកិច្ចការនៅផ្ទះ និងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀន | | | |
| ៥ | **ដំណើរការបណ្ណាល័យ** | | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| ៥.១ | សាលាបានរៀបចំបណ្ណាល័យត្រឹមត្រូវ និងដំណើរការជាប្រចាំ | - សាលារៀនមានបណ្ណាល័យ ដែលកុមារអាចអនុវត្តសកម្មភាពបាន(បន្ទប់ដាច់ដោយឡែកឬផ្នែកមួយនៃជ្រុងទីចាត់ការឬថ្នាក់រៀន )<br>- សាលារៀនមានដាក់តាំងសៀវភៅច្រើនប្រភេទស្របតាមវ័យកុមារ<br>- សាលារៀនមានចាត់តាំងឱ្យមានបណ្ណារក្សជាប្រចាំ<br>- សាលារៀនមានរៀបចំបញ្ជីរួម បញ្ជីសារពើភណ្ឌ បញ្ជីខ្ចី និងបញ្ជីសង<br>- សាលារៀនមានរៀបចំកាលវិភាគចូលបណ្ណាល័យ<br>- សាលារៀនមានបញ្ជីឈ្មោះកុមារចូលបណ្ណាល័យ | | |
| ៦ | **សាលារៀនបានធ្វើអធិការកិច្ចផ្ទៃក្នុងត្រឹមត្រូវតាមផែនការកំណត់** | | | |
| ៦.១ | ភាគរយថ្នាក់រៀននាយកបានចុះអធិការកិច្ចសង្កេតការបង្រៀន | - សាលារៀនមានផែនការអធិការកិច្ចការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀនសម្រាប់ឆ្នាំសិក្សា<br>- នាយកសាលារៀនបានចុះសង្កេតការបង្រៀនឆ្លើយតបតាមផែនការ<br>- សាលារៀនមានរបាយការណ៍អធិការកិច្ចការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀនរបស់គ្រូបង្រៀន<br>- សាលារៀនមានគ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យ<br>- សាលារៀនមានគ្រូបង្រៀនទទួលបានការធ្វើអធិការកិច្ច ផ្ទៃក្នុងយ៉ាងតិច១ដងក្នុង១ឆ្នាំ | | |
| ៧ | **ការប្រជុំបច្ចេកទេស** | | | |
| ៧.១ | សាលារៀនបានរៀបចំការប្រជុំបច្ចេកទេសទៀងទាត់តាមផែនការរបស់សាលារៀន | - សាលារៀនមានផែនការការប្រជុំប្រចាំខែឆ្នាំ<br>- សាលារៀនមានរបាយការណ៍/កំណត់ហេតុប្រជុំ និងបញ្ជីវត្តមាន | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| ៨ | ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា | | | |
| ៨.១ | សាលារៀនបានរៀបចំកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ នៅសាលាបឋមសិក្សា ឬតំបន់ផ្សេងៗ | - សាលារៀនមានផែនការទស្សនកិច្ចសិក្សារបស់កុមារអាយុ៥ឆ្នាំ<br>- សាលារៀនមានកិច្ចព្រមព្រៀងរវាងសាលាមត្តេយ្យ និងសាលាបឋមសិក្សា<br>- សាលារៀនមានរៀបចំបញ្ជីឈ្មោះកុមារអាយុ៥ឆ្នាំ និងមាតាបិតា<br>- សាលារៀនមានប្រជុំផ្សព្វផ្សាយជាមួយមាតាបិតា<br>- សាលារៀនមានរបាយការណ៍ | | |
| ៨.២ | សាលាមានបង្កើតកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់មត្តេយ្យសិក្សា | - សាលារៀនមានផែនការប្រជុំជាមួយមាតាបិតាប្រចាំឆ្នាំ<br>- សាលារៀនមានកំណត់ហេតុប្រជុំ បញ្ជីវត្តមាន<br>- សាលារៀនមានរចនាសម្ព័ន្ធកម្មវិធី<br>- សាលារៀនមានឯកសារម៉ូឌុលអប់រំមាតាបិតា | | |
| ៨.៣ | សាលាមានកម្មវិធីប្រឹក្សាគរុកោសល្យជាមួយគ្រូសាលាមត្តេយ្យសិក្សា/មត្តេយ្យសិក្សាឯកជន/ថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា | - សាលារៀនមានរចនាសម្ព័ន្ធបណ្តាញសាលាក្នុងសហគមន៍<br>- សាលារៀនមានផែនការប្រចាំឆ្នាំការជួយសាលារៀន ក្នុងបណ្តាញ<br>- សាលារៀនមានកិច្ចព្រមព្រៀងជាមួយសាលារៀន<br>- សាលារៀនមានកំណត់ហេតុប្រជុំ បញ្ជីវត្តមាន | | |
| ៨.៤ | សាលារៀនមានរៀបចំព្រឹត្តិការណ៍បង្ហាញទេពកោសល្យកុមារ និងមាតាបិតា | - សាលារៀនមានផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំ<br>- សាលារៀនមានរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ | | |
| ៩ | ការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌ | | | |
| ៩.១ | សាលារៀនបានអនុវត្តកម្មវិធីការអប់រំសីលធម៌ និងចរិយាធម៌( ការអប់រំកុមារពីរបៀបនៃការសំពះ ការគួរសម ការអប់រំវេរិយាបទដេក ដើរ | - សាលារៀនមានអនុវត្តការអប់រំចិត្តសង្គមកុមារ<br>- សាលារៀនមានកម្មវិធីអប់រំផ្លូវចិត្តមាតា | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| | ឈរ អង្គុយ និងការប្រើពាក្យសំដី) | បិតា អ្នកអាណាព្យាបាល<br>- សាលារៀនមានរៀបចំ កម្មវិធីអប់រំបែបពុទ្ធសាសនា<br>- សៀវភៅតាមដានការសិក្សាមានការផ្តល់មូលវាចារលើការអប់រំចរិយាធម៌កុមារ<br>- របាយការណ៍ស្តីពីការអនុវត្តនិងការពិនិត្យតាមដាន និងជំរុញការអនុវត្ត | | |
| ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ | | | | |
| ១ | ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន | | | |
| ១.១ | ចំនួនដងគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស.)ប្រជុំក្នុងមួយឆ្នាំ | - សាលារៀនមានរបាយការណ៍ប្រជុំស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន<br>- លិខិតបង្គាប់ការគណៈកម្មការគ្រប់គ្រងសាលារៀនមានការទទួលស្គាល់តាមការណែនាំ<br>- របនាសម្ព័ន្ធនិងតួនាទីភារកិច្ចច្បាស់លាស់តាមការណែនាំ<br>- របាយការណ៍ប្រជុំ និងរបាយការណ៍វឌ្ឍនភាពតាមការណែនាំ<br>- របាយការណ៍បង្ហាញអំពីការគាំទ្រឱ្យសាលារៀនមានការអភិវឌ្ឍទាំងលទ្ធផលសិក្សារបស់កុមារ និងការកែលម្អបរិស្ថានសាលារៀន | | |
| ២ | ការចូលរួមរបស់សហគមន៍ | | | |
| ២.១ | ភាគរយមាតាបិតា អ្នកអាណាព្យាបាលចូលរួមប្រជុំតាមការអញ្ជើញរបស់នាយកសាលា | - សហគមន៍បានចូលរួមប្រជុំទៀងទាត់តាមផែនការ<br>- សហគមន៍ចូលរួមរៀបចំបរិស្ថានបៃតងអនាម័យ អគារសិក្សា បន្ទប់រៀន សម្ភារិម និងបរិក្ខារសិក្សាបាន ថែរក្សានិងពង្រីកបន្ថែមតាមបែបបច្ចេកវិទ្យា | | |
| ២.២ | សាលារៀនមានសកម្មភាពកិច្ចសហការបច្ចេកទេសជាមួយភាពជាដៃគូវិនិយោគរវាងវិស័យសាធារណៈ វិស័យឯកជន និងដៃគូ | - សាលារៀនមានកិច្ចព្រមព្រៀងជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| | អភិវឌ្ឍលើការរៀបចំអាហារសម្រន់ ឬ អាហារតាមសាលារៀន, កន្លែងក្មេងលេង | | | |
| ៣ | ការគាំទ្ររបស់សហគមន៍ | | | |
| ៣.១ | សហគមន៍បានចូលរួមជួយគាំទ្រ មូលនិធិ ដំណើរការសាលារៀន និងសកម្មភាពរបស់សាលារៀន | - សាលារៀនមានបញ្ជីរបាយការណ៍ចំណូលចំណាយថវិកា<br>- សាលារៀនមានបញ្ជីរបាយការណ៍សម្ភារៈ<br>- សាលារៀនកត់ត្រាសកម្មភាពរបស់សហគមន៍ចូលរួមជួយរៀបចំអានាម័យ និងការថែទាំបរិស្ថាន<br>- សាលារៀនកត់ត្រាសកម្មភាពរបស់សហគមន៍ចូលរួមជួយរៀបចំសន្តិសុខ និងសណ្តាប់សាលារៀន<br>- របាយការណ៍បូកសរុបការគាំទ្ររបស់សហគមន៍ប្រចាំ | | |
| ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | | | | |
| ១ | ការគ្រប់គ្រងទូទៅ និងរដ្ឋបាល | | | |
| ១.១ | សាលារៀនបានរៀបចំការគ្រប់គ្រងទូទៅ និងរដ្ឋបាលបានល្អប្រសើរ | - សាលារៀនមានរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងត្រឹមត្រូវ<br>- សាលារៀនមានរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសាលារៀន<br>- សាលារៀនមានបចំណែងចែកតួនាទីភារកិច្ចបុគ្គលិក<br>- សាលារៀនមានស្ថិតិបុគ្គលិកអប់រំ និងកុមារ<br>- បញ្ជីសម្ភារៈ និងសាពើភ័ណ្ឌ | | |
| ១.២ | សាលារៀនប្រើប្រាស់ App សម្រាប់គ្រប់គ្រងទិន្នន័យសាលារៀន | - សាលារៀនប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ(FMIS)<br>- សាលារៀនមានAppសម្រាប់គ្រប់គ្រងទិន្នន័យរបស់សាលារៀន<br>- សាលារៀនមានអ្នកគ្រប់គ្រងទិន្នន័យ និងអាចទាញយកជារបាយការណ៍តាមតម្រូវការ<br>- នាយកសាលាធានាសុចរិតភាពនៃ | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| | | ទិន្នន័យដែលបានបញ្ចូលទៅក្នុងប្រព័ន្ធ ឬ App<br>- ទិន្នន័យរបស់សាលារៀនត្រូវបានផ្សព្វផ្សាយដល់សាធារណៈជន ជាពិសេសមាតាបិតា អ្នកអាណាព្យាបាល សហគមន៍ និងអាជ្ញាធរដែនដី | | |
| ១.៣ | ចំនួនគ្រូបង្រៀនខ្វះត្រូវបានដោះស្រាយ | - សាលារៀនមានបញ្ជីគណៈគ្រប់គ្រងនិងគ្រូបង្រៀនលើស ឬខ្វះ | | |
| ២.៤ | សាលារៀនមានកម្មវិធីប្រជុំប្រចាំខែ ត្រីមាស និងឆមាសត្រឹមត្រូវ | - សាលារៀនមានផែនការសកម្មភាពការងារ<br>- សាលារៀនមានកម្មវិធីប្រជុំប្រចាំខែ ត្រីមាស និងឆមាស | | |
| ២.៥ | សាលារៀនបានរៀបចំរបាយការណ៍ត្រឹមត្រូវតាមការណែនាំ | - សាលារៀនមានរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស<br>- របាយការណ៍សកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ | | |
| ២ | ការរៀបចំផែនការអភិវឌ្ឍសាលារៀន | | | |
| ២.១ | សាលារៀនបានរៀបចំផែនការត្រឹមត្រូវ | - សាលារៀនមានចក្ខុវិស័យ បេសកកម្មយុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះ<br>- សាលារៀនមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ៥ឆ្នាំ<br>- ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ<br>- ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការថវិកាប្រចាំឆ្នាំ<br>- សាលារៀនមានផែនការកែលម្អសាលារៀនបានអនុម័តជាផ្លូវការ | | |
| ៣ | ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក | | | |
| ៣.១ | ភាគរយគ្រូបង្រៀន និងបុគ្គលិកអប់រំបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ | - កិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំរវាងនាយកសាលារៀន និងគ្រូបង្រៀននិងបុគ្គលិកអប់រំ<br>- កិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំរវាងគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រង | | |
| ៣.២ | ចំនួននាយកសាលានិងនាយករងបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ | | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | - សាលារៀនមានប្រព័ន្ធវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀនប្រចាំឆ្នាំ<br>- សាលារៀនមានគ្រូបង្រៀនចូលរៀនវគ្គការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ(វិធីសាស្ត្របង្រៀន ការប្រឹក្សាគរុកោសល្យ...)<br>- សាលារៀនមានកម្មវិធីលើកទឹកចិត្ត( ការលើកសរសើរ ទស្សនកិច្ចសិក្សាសម្រាប់គ្រូ ទៅសាលាផ្សេងក្នុងឆ្នាំសិក្សា ) | | |
| ៤ | **វង្វាយតម្លៃលទ្ធផលសិក្សា** | | | |
| ៤.១ | ភាគរយថ្នាក់រៀនបានអនុវត្តការវាយតម្លៃលទ្ធផលសិក្សារបស់កុមារតាមកម្មវិធីសិក្សាត្រឹមត្រូវ | - សាលារៀនបានរៀបចំរបៀបរបបវាយតម្លៃលទ្ធផលសិក្សាកុមារតាមកម្មវិធីសិក្សា<br>- សាលារៀនមានផែនការជួយកុមារអភិវឌ្ឍន៍យឺត<br>- សាលារៀនមានបញ្ជីវាយតម្លៃការអភិវឌ្ឍសមត្ថភាពកុមារតាមកម្រិតថ្នាក់<br>- សាលារៀនបានអនុវត្តការវាយតម្លៃកុមារ<br>- សាលារៀនមានបញ្ជីលទ្ធផលនៃការវាយតម្លៃការអភិវឌ្ឍសមត្ថភាពកុមារ | | |
| ៥ | **ការលើកកម្ពស់សុខភាពសិក្សា និងអាហារូបត្ថម្ភ** | | | |
| ៥.១ | ការលើកកម្ពស់សេវាថែទាំសុខភាពបឋម | - គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាមានសមាសភាព តួនាទីភារកិច្ចច្បាស់លាស់ និងមាននីត្យានុកូល<br>- ភស្តុតាងនៃបរិក្ខារនិងសម្ភារៈសង្គ្រោះបឋម<br>- របាយការណ៍ស្តីពីការផ្តល់ថ្នាំបង្ការតាមកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ឬថ្នាំទម្លាក់ដង្កូវព្រូន<br>- បន្ទប់សុខភាពនិងសម្ភារៈប្រើប្រាស់ជាមូលដ្ឋានចាំបាច់<br>- យន្តការគ្រប់គ្រងកិច្ចដំណើរការបន្ទប់សុខភាព | | |
| ៥.២ | សាលារៀនបានរៀបចំកម្មវិធីពិនិត្យសុខភាព | - ផែនការពិនិត្យសុខភាពកុមារ | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | កុមារ | - សៀវភៅតាមដានសុខភាពកុមារ<br>- របាយការណ៍ទិន្នន័យស្តីពីការពិនិត្យសុខភាពកុមារ ឬការផ្តល់សេវាសុខភាពផ្សេងៗ<br>- របាយការណ៍ស្តីពីកិច្ចអន្តរាគមន៍ចំពោះសិស្សដែលមានបញ្ហាសុខភាពមិនល្អបានទៅទទួលសេវាគាំទ្រ | | |
| ៥.៣ | ការលើកកម្ពស់ទឹកស្អាត និងអនាម័យ | - បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ បណ្តាញទឹកស្អាត<br>- កម្មវិធីការគ្រប់គ្រងអនាម័យ<br>- បណ្តាញទឹកស្អាតសម្រាប់ទទួលទានរបស់គ្រូ កុមារ<br>- កាលវិភាគស្តីពីការលាងសម្អាតដៃនិងដុសសម្អាតធ្មេញជាក្រុមសម្រាប់កុមារទាំងអស់ | | |
| ៥.៤ | ការលើកកម្ពស់សុវត្ថិភាពចំណីអាហារប្រកបដោយសុខភាព | - ការបិទផ្សាយគោលការណ៍ណែនាំស្តីពីការលើកកម្ពស់ សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព<br>- អ្នកលក់មានកិច្ចសន្យាច្បាស់លាស់ជាមួយនាយកសាលា ឬអាជ្ញាធរមានសមត្ថកិច្ច<br>- យន្តការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ និងអាហារ ប្រកបដោយសុខភាព | | |
| ៥.៥ | ការអនុវត្តកម្មវិធីអប់រំសុខភាព | - ផែនការបង្រៀន និងកាលវិភាគ អប់រំសុខភាព<br>- សៀវភៅតាមដានការអប់រំសុខភាព<br>- របាយការណ៍ពីការអប់រំផ្សព្វផ្សាយពីសារសុខភាពផ្សេងៗគ្រប់រូបភាព<br>- របាយការណ៍លទ្ធផលអប់រំសុខភាព | | |
| ៥.៦ | ការលើកកម្ពស់បរិស្ថានស្អាតបៃតង សុវត្ថិភាព អនាម័យ និងមេត្រីភាព | - ធុងសំរាមបានរៀបចំស្របតាមលក្ខណៈបច្ចេកទេស ឬមានឡដុតសំរាមតាមស្តង់ដាបច្ចេកទេស<br>- សួនផ្កាលម្អ រុក្ខជាតិ ដើមឈើ សួនបន្លែ | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ឥស្សតាង | ពិន្ទុ |
| | | របងជុំ សួនដីរ:ចម្រុះ<br>- យន្តការត្រួតពិនិត្យនិងការសម្អាតអនាម័យ<br>- សាលារៀនគ្មានប្រើប្រាស់ថង់ប្លាស្ទីក | | |
| ៥.៧ | ការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ ការការពារកុមារ ការបង្ការគ្រោះមហន្តរាយនានា | - សាលារៀនមានរបង ទ្វារចេញចូល<br>- សាលារៀនមានប្រព័ន្ធកិច្ចការពារកុមារ ការរៀបចំយន្តការសណ្ដាប់ធ្នាប់ រក្សាសុវត្ថិភាព ការដាក់ស្លាកសញ្ញាចរាចរណ៍ ការបង្ការការលង់ទឹក សម្ភារ:បរិក្ខារ ជូនដំណឹងពីសញ្ញាគ្រោះថ្នាក់ បំពង់ពន្លត់អគ្គីភ័យ | | |
| ៥.៨ | សាលារៀនបានអនុវត្តសកម្មភាពអប់រំកាយនិងកីឡា | - ទីធ្លាសម្រាប់ធ្វើសកម្មភាពអប់រំកាយនិងកីឡា<br>- តារាងវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សពីអប់រំកាយនិងកីឡា | | |
| ៦ | **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ** | | | |
| ៦.១ | សាលារៀនមានសួនកុមារ និងសម្ភារ:សម្រាប់កុមារលេងដោយសេរី និងមានសុវត្ថិភាព | សាលារៀនមានសួនកុមារ និងសម្ភារ:សម្រាប់កុមារលេង ដោយសេរី និងមានសុវត្ថិភាព៖<br>- របងសុវត្ថិភាព<br>- ស្លាកឈ្មោះ<br>- សម្ភារ:ល្បែង<br>- ការប្រើប្រាស់ពណ៌<br>- ការរៀបចំស្លាកសញ្ញាសម្គាល់ | | |
| ៦.២ | ភាគរយថ្នាក់រៀនមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំល្អប្រសើរ | - សាលារៀនមានបណ្ដាញអគ្គិសនីបំពាក់អ៊ិនធើណេត<br>- បន្ទប់សុខភាព<br>- អាហារដ្ឋាន និងបង្គន់អនាម័យ<br>- សាលារៀនមានបន្ទប់កុំព្យូទ័រ និងបណ្ណាល័យ<br>- បន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប ( LCD, Smart TV, Smart Boad ) | | |
| **ស្តង់ដាទី៥៖ គណនេយ្យភាពរបស់សាលារៀន** | | | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| ១ | វេទិកាសាធារណៈ | | | |
| ១.១ | សាលារៀនរៀបចំកម្មវិធីជួបជុំជាមួយមាតាបិតា អ្នកអាណាព្យាបាលកុមារ និងសហគមន៍ | - សាលារៀនមានផែនការប្រចាំឆ្នាំ<br>- សាលារៀនមានរបាយការណ៍លទ្ធផល<br>- សាលារៀនមានបញ្ជីវត្តមានអ្នកចូលរួម | | |
| ២ | ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ | | | |
| ២.១ | សាលារៀនបានផ្សព្វផ្សាយព័ត៌មានជាសាធារណៈតាមការណែនាំ | - សាលារៀនមានផែនការសាលារៀន<br>- សាលារៀនមានបិទផ្សាយឯកសារសកម្មភាព ឬស្នាដៃកុមារ និងព័ត៌មានផ្សេងៗ<br>- សាលារៀនបានផ្តល់របាយការណ៍លទ្ធផលនៃការអភិវឌ្ឍរបស់កុមារយើត ឱ្យមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍<br>- សាលារៀនមានសកម្មភាពការងាររបស់សាលារៀន<br>- សាលារៀនមានរបាយការណ៍ការងារប្រចាំខែ ប្រចាំ ត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ | | |
| ៣ | ការទទួលបានការគាំទ្រពីថ្នាក់ជាតិ | | | |
| ៣.១ | ចំនួននាយក និងនាយករង បានទទួលការហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធីសាលារៀនគំរូ | - សាលារៀនមានបញ្ជីរាយនាមនាយកនាយករងទទួលការហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធីសាលារៀនគំរូ<br>- សាលារៀនមានរបាយការណ៍លទ្ធផលនៃការអនុវត្ត | | |
| ៣.២ | សាលារៀនបានទទួលការចុះពិនិត្យតាមដាន និងផ្តល់ការគាំទ្រពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | - សាលារៀនមានគ្រូបង្រៀន ក្រុមបច្ចេកទេស និង គណៈគ្រប់គ្រងសាលារៀន មានបញ្ជីកត់ត្រាជំនួយ បច្ចេកទេសពីថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ<br>- សាលារៀនមានតារាងកត់ត្រាទិន្នន័យព័ត៌មាន និងផ្តល់យោបល់ពីការជួយសម្រាប់សាលារៀនក្នុងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនពីថ្នាក់ | | |

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្គុគាខ | ពិន្ទុ |
| | | ក្រោមជាតិ ថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធ | | |
| សរុបពិន្ទុ | | | | |

## ៦. គោលការណ៍ណែនាំអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

**ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស**

ស្តង់ដានៃលទ្ធផលសិក្សារបស់សិស្សគឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពរបស់សាលាមត្តេយ្យសិក្សា ដោយផ្តោតលើផលសម្រេចក្នុងឆ្នាំនៃសកម្មភាពចាំបាច់ ដែលសាលារៀនត្រូវផ្តោតការយកចិត្តទុកដាក់ប្រមូលកុមារអាយុ៣ឆ្នាំ ទៅក្រោម៦ឆ្នាំឱ្យបានចូលរៀនតាមផែនការកំណត់ ការធានាឱ្យបានសម្រាប់កុមាររៀនសូត្របានពេញលេញ ក្នុងនោះសាលារៀនត្រូវកំណត់យកលទ្ធផលសិក្សារបស់កុមារ ដោយផ្អែកលើការអភិវឌ្ឍផ្នែកទាំង៥របស់កុមារ ព្រមទាំងរិះរកវិធានការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងការអប់រំសីលធម៌ និងឥរិយាបថរបស់កុមារ។ សាលារៀនផ្តោតការយកចិត្តទុកដាក់ និងកំណត់យកលទ្ធផលសិក្សារបស់កុមារជាគោលដើម្បីធ្វើការអភិវឌ្ឍសាលារៀន។

១. **ការប្រមូលកុមារចូលរៀន៖** សាលារៀនត្រូវប្រមូលកុមារចូលរៀនតាមកម្រិតអាយុ ៣ឆ្នាំ ៤ឆ្នាំ និង៥ឆ្នាំ ឱ្យបានតាមចំណុចប្រចាំឆ្នាំ។ ដូច្នេះសាលាត្រូវរៀបចំឱ្យមានដូចខាងក្រោម៖

- **ការចូលរៀនរបស់កុមារអាយុ ៥ឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - រៀបចំបញ្ជីស្ថិតិកុមារអាយុ៥ឆ្នាំ ក្នុងភូមិសាស្ត្រសិក្សារបស់សាលាមត្តេយ្យសិក្សា ដើម្បីជាមូលដ្ឋានក្នុងការកំណត់ចំនួនកុមារអាយុ ៥ឆ្នាំដែលបានចូលរៀនធៀបនឹងចំនួនកុមារក្នុងស្ថិតិប្រជាជនអាយុ៥ឆ្នាំ
  - សាលារៀនមានស្ថិតិកុមារអាយុ៥ឆ្នាំចូលរៀននៅដើមឆ្នាំសិក្សា(ភូមិចំណុះសាលារៀន)
  - ផែនទី និងទិន្នន័យខ្នងផ្ទះ
  - សំបុត្រកំណើតកុមារ និងសៀវភៅគ្រួសារកុមារ
  - តារាង/បញ្ជីឈ្មោះកុមារតាមគ្រួសារ(ភូមិចំណុះសាលារៀន)
- **ការចូលរៀនរបស់កុមារអាយុ ៤ឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - រៀបចំបញ្ជីស្ថិតិកុមារអាយុ៤ឆ្នាំ ក្នុងភូមិសាស្ត្រសិក្សារបស់សាលាមត្តេយ្យសិក្សា ដើម្បីជាមូលដ្ឋានក្នុងការកំណត់ចំនួនកុមារអាយុ៤ឆ្នាំ ដែលបានចូលរៀនធៀបនឹងចំនួនកុមារក្នុងស្ថិតិប្រជាជនអាយុ៤ឆ្នាំ
  - សាលារៀនមានស្ថិតិកុមារអាយុ៥ឆ្នាំ ចូលរៀននៅដើមឆ្នាំសិក្សា(ភូមិចំណុះសាលារៀន)

- ផែនទី និងទិន្នន័យខ្នងផ្ទះ
- សំបុត្រកំណើតកុមារ និងសៀវភៅគ្រួសារកុមារ
- តារាង/បញ្ជីឈ្មោះកុមារតាមគ្រួសារ(ភូមិចំណុះសាលារៀន)

– **ការចូលរៀនរបស់កុមារអាយុ ៣ឆ្នាំ សាលារៀនត្រូវរៀបចំ៖**

- រៀបចំបញ្ជីស្ថិតិកុមារអាយុ៣ឆ្នាំ ក្នុងភូមិសាស្ត្រសិក្សារបស់សាលាមត្តេយ្យសិក្សា ដើម្បីជាមូលដ្ឋានក្នុងការកំណត់ចំនួនកុមារអាយុ៥ឆ្នាំ ដែលបានចូលរៀនធៀបនឹងចំនួនកុមារក្នុងស្ថិតិប្រជាជនអាយុ៣ឆ្នាំ
- សាលារៀនមានស្ថិតិកុមារអាយុ៣ឆ្នាំចូលរៀននៅដើមឆ្នាំសិក្សា(ភូមិចំណុះសាលារៀន)
- ផែនទី និងទិន្នន័យខ្នងផ្ទះ
- សំបុត្រកំណើតកុមារ និងសៀវភៅគ្រួសារកុមារ
- តារាង/បញ្ជីឈ្មោះកុមារតាមគ្រួសារ(ភូមិចំណុះសាលារៀន)

២. **កុមាររៀនបានគង់វង្សក្នុងសាលារៀន៖** សាលារៀនត្រូវចាត់វិធានការសមស្របដើម្បីធានាឱ្យបានសម្រាប់កុមារអាយុ៥ឆ្នាំ រៀនសូត្របានពេញលេញគ្រប់តាមកម្មវិធីសិក្សានៅក្នុងឆ្នាំសិក្សា។ សាលារៀនត្រូវរៀបចំតាមដានការសិក្សា ដោយកត់ត្រាស្រង់ចូលតារាងទិន្នន័យស្ថិតិកុមារអាយុ៥ឆ្នាំ នៅដំណាច់ឆ្នាំសិក្សា និងត្រូវធ្វើផលធៀបទិន្នន័យបវេសនកាល និងដំណាច់ឆ្នាំសិក្សា។

– **កុមារអាយុ៥ឆ្នាំ បានឆ្លងកាត់មត្តេយ្យសិក្សា និងទៅចូលរៀនថ្នាក់ទី១ នៅសាលាបឋមសិក្សា សាលារៀនត្រូវរៀបចំ៖**

- របាយការណ៍ស្តីពីចំនួនសិស្សអាយុ៦ឆ្នាំដែលបានចូលរៀនថ្នាក់ទី១ និងធ្លាប់បានឆ្លងកាត់មត្តេយ្យសិក្សា(ប្រភពចេញពីសាលាមត្តេយ្យសិក្សាសាមី) ធៀបនឹងចំនួនសិស្សថ្នាក់ទី១
- សាលារៀនរៀបចំនិងរក្សាទុកបញ្ជីស្ថិតិបញ្ជីបញ្ជូនកុមារអាយុ៥ឆ្នាំ ចូលរៀនថ្នាក់ទី១ សាលាបឋមសិក្សាប្រចាំឆ្នាំសិក្សា។

៣. **លទ្ធផលនៃការសិក្សារបស់សិស្ស៖** លទ្ធផលសិក្សារបស់កុមារ គឺការអភិវឌ្ឍនៃផ្នែកទាំង៥ របស់កុមារ។ សាលាមត្តេយ្យសិក្សា ត្រូវយកចិត្តទុកដាក់ពិនិត្យតាមដានការបង្រៀននិងរៀន ដោយរៀបចំផែនការច្បាស់លាស់ក្នុងការជួយគ្រូបង្រៀន ដើម្បីការប្រែប្រួលការអភិវឌ្ឍរបស់កុមារ ក្នុងន័យនេះ សាលាត្រូវរិះរកមធ្យោបាយរៀបចំជារបាយការណ៍វាយតម្លៃលទ្ធផលនៃការសិក្សាកុមារ៥ឆ្នាំឱ្យបានជាក់លាក់ និងរក្សាទុកដាក់ឱ្យបានត្រឹមត្រូវប្រចាំឆ្នាំសិក្សានីមួយ។ សាលាមត្តេយ្យសិក្សាត្រូវរៀបចំគណនាភាគរយលទ្ធផលសិក្សាប្រចាំឆ្នាំសិក្សារបស់កុមារ និងរក្សាទុកឱ្យបានត្រឹមត្រូវ៖

– **កុមារអាយុ ៥ឆ្នាំ មានការអភិវឌ្ឍ ផ្នែកទាំង៥ បានល្អប្រសើរសាលារៀនត្រូវរៀបចំ៖**

- របាយការណ៍វាយតម្លៃលទ្ធផលនៃការសិក្សាកុមារ៥ឆ្នាំ ប្រចាំឆ្នាំសិក្សាដោយផ្អែកតាមស្តង់លទ្ធផលសិក្សារបស់កុមារ។

៤. **ស្ថានភាពអាហារូបត្ថម្ភរបស់សិស្ស៖** សាលារៀនត្រូវជំរុញ និងចាត់វិធានការត្រួតពិនិត្យតាមដានជាប្រចាំលើស្ថានភាពអាហារូបត្ថម្ភកុមារ ដែលកំពុងសិក្សារៀនក្នុងឆ្នាំសិក្សាដើម្បីលើកកម្ពស់សុខមាលភាពកុមារកាន់តែប្រសើរឡើង។ សាលារៀនត្រូវរៀបចំបញ្ជីកត់ត្រាអំពីស្ថានភាពអាហារូបត្ថម្ភរបស់កុមារតាមប័ណ្ណសុខភាពកុមារី និងកុមារា(ថ្លឹងទម្ងន់ វាស់កម្ពស់) និងត្រូវរក្សាទុកដាក់ជាឯកសារភស្តុតាងឱ្យត្រឹមត្រូវប្រចាំសាលាតាមកម្រិតអាយុកុមារ ដើម្បីបង្ហាញដល់មាតាបិតា អ្នកអាណាព្យាបាល ផ្តល់ការកោតសរសើរ ឬផ្តល់បទអន្តរាគមន៍ជួយកុមារបានទាន់ពេលវេលា។

- **កុមារមានស្ថានភាពអាហារូបត្ថម្ភធម្មតា សាលារៀនត្រូវរៀបចំ៖**
  - បញ្ជីកត់ត្រាស្ថានភាពអាហារូបត្ថម្ភកុមារ(អាយុ ទម្ងន់ កម្ពស់)
  - សៀវភៅតាមដានសុខភាពកុមារម្នាក់ៗ
- **កុមារដែលមានបញ្ហាអាហារូបត្ថម្ភទទួលបានកិច្ចអន្តរាគមន៍ សាលារៀនត្រូវរៀបចំ៖**
  - របាយការណ៍ត្រឡប់ពីមាតាបិតាឬអ្នកអាណាព្យាបាល ក្នុងការសហការជួយអន្តរាគមន៍ ឬការនាំកុមារទៅរកសេវាគាំទ្រ
  - របាយការណ៍ពីកិច្ចអន្តរាគមន៍របស់សេវាសុខាភិបាលមូលដ្ឋានតាមរយៈគណៈកម្មការសុខភាពសិក្សាតាមសាលារៀន
- **ភាគរយសិស្សក្រីក្រទទួលបានការឧបត្ថម្ភនានាសាលារៀនត្រូវរៀបចំ៖**
  - របាយការណ៍ស្តីពីការផ្តល់ការឧបត្ថម្ភនានារបស់កម្មវិធីជាតិ ឬកម្មវិធីគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ឬសប្បុរសជននានា

៥. **សីលធម៌ និងឥរិយាបថរបស់សិស្ស៖** សាលារៀនរៀបចំសកម្មភាពក្នុងអប់រំឥរិយាបថរបស់សមាជិកគ្រួសារកុមារដើម្បីកាត់បន្ថយហិង្សាក្នុងគ្រួសារឱ្យមានការថយចុះ និងផ្តល់កិច្ចគាំពារនិងអន្តរាគមន៍។ សកម្មភាពចាំបាច់សំខាន់ៗ ដែលសាលារៀនត្រូវរៀបចំនិងអនុវត្តមានដូចខាងក្រោម៖

- **កុមារទទួលកិច្ចគាំពារនិងអន្តរាគមន៍ សាលារៀនត្រូវរៀបចំ៖**
  - បញ្ជីព័ត៌មានកត់ត្រាចំនួនកុមាររងហិង្សា(ដូចជាហិង្សាផ្លូវកាយ ហិង្សាផ្លូវចិត្ត ហិង្សាផ្លូវភេទ និងការមិនអើពើ)សាលារៀនមានផែនការប្រឹក្សាយោបល់ជាមួយមាតាបិតា អ្នកអាណាព្យាបាល
  - របាយការណ៍ទទួលបានពីក្រុមបណ្តាញឪពុកម្តាយ និងគណៈកម្មការកិច្ចការនារីនិងកុមារឃុំ សង្កាត់(គ.ក.ន.ក.)
  - របាយការណ៍ និងបញ្ជីវត្តមានលើការប្រឹក្សាយោបល់ជាមួយមាតាបិតា អ្នកអាណាព្យាបាល
- **អនុវត្តកម្មវិធីទម្លាប់ល្អ(សីលធម៌ និងឥរិយាបថកុមារ) ជាប្រចាំ សាលារៀនត្រូវរៀបចំ៖**
  - របាយការណ៍ និងការចុះពិនិត្យវាយតម្លៃជាក់ស្តែង
  - បញ្ជីលទ្ធផលសៀវភៅតាមដានការសិក្សា។

**ស្តង់ដាទី២៖ ការបង្រៀននិងរៀន**

ស្តង់ដានៃការបង្រៀននិងរៀនគឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមត្តេយ្យសិក្សានៃសកម្មភាពចាំបាច់ ដែលសាលារៀនត្រូវផ្តោតការយកចិត្តទុកដាក់លើការអនុវត្តវិធីសាស្ត្របង្រៀនថ្មីឱ្យបានសមស្របនិងមានប្រសិទ្ធភាព ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន ការផលិតសម្ភារៈបង្រៀននិងរៀន ការជួយគាំទ្រកុមារ ការរៀបចំដំណើរការបណ្ណាល័យ ការធ្វើអធិការកិច្ចផ្ទៃក្នុងលើកការបង្រៀននិងរៀន ការប្រជុំបច្ចេកទេស ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា និងការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌។ ស្តង់ដានៃការបង្រៀននិងរៀនសម្រាប់សាលាមត្តេយ្យសិក្សាគំរូត្រូវបានកំណត់ជាសូចនាករគន្លឹះ និងសូចនាកររងដូចខាងក្រោម៖

១. **ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី៖** សាលារៀនត្រូវផ្តោតការយកចិត្តទុកដាក់លើដំណើរការបង្រៀននិងរៀន ដោយគ្រូបង្រៀនត្រូវចេះនិងអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ គឺ***ការរៀនតាមរយៈការលេង (Learning Throught Play)*** ការសិក្សាតាមបែបគម្រោង និងការរៀនសម្របតាមសមត្ថភាពកុមារ (Adaptive learning system) ដោយឈរលើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ព្រមទាំងដាក់កិច្ចការឱ្យកុមារធ្វើនិងកែកិច្ចការកុមារ។ សាលារៀន និងថ្នាក់រៀន ***ត្រូវយកចិត្តដាក់ប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀននិងរៀន*** ឱ្យបានសមស្រប។

- **ការអនុវត្តការរៀនតាមរយៈការលេង (Learning Throught Play) សាលារៀនត្រូវរៀបចំ៖**
  - ផែនការសកម្មភាពលេងតាមប្រធានបទ
  - តារាងរបាយម៉ោងសិក្សាអនុវត្តការលេងដោយសេរី ការលេងដោយមានការណែនាំ និងការលេងល្បែងសិក្សាតាមកម្មវិធីសិក្សាពេញលេញ
  - បញ្ជីសម្ភារៈល្បែងសិក្សា
  - សម្ភារៈល្បែងសិក្សារៀបចំតាមជ្រុងថ្នាក់រៀន
  - ឯកសារសកម្មភាពរបស់កុមារម្នាក់ៗ(Portfolio)
- **ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀននិងរៀន សាលារៀនត្រូវរៀបចំ៖**
  - រៀបចំបន្ទប់កុំព្យូទ័រនិងបណ្ណាល័យ
  - រៀបចំបន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប(LCD, Smart TV, Smart Boad)

២. **ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន៖** សាលារៀនអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន ដោយគ្រូបង្រៀនត្រូវរៀបចំបំណែងចែកកម្មវិធីសិក្សាតាមកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា និងធ្វើបច្ចុប្បន្នកម្មកិច្ចតែងការបង្រៀន។ សាលារៀន និងថ្នាក់រៀនត្រូវអនុវត្តកម្មវិធីសិក្សាឱ្យបានត្រឹមត្រូវ ដោយកំណត់របបប្រជុំវាយតម្លៃការអនុវត្តកម្មវិធីសិក្សាប្រចាំឆមាស និងប្រចាំឆ្នាំ។ សាលារៀននិងថ្នាក់រៀនដំណើរការស្របតាមនិយាមម៉ោងកំណត់ត្រឹមត្រូវដោយកាត់បន្ថយការបិទទ្វារសាលារៀនមិនប្រក្រតី អវត្តមានគ្រូ និងអវត្តមានកុមារ។

- **ការរៀបចំបំណែងចែកកម្មវិធីសិក្សាតាមកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា សាលារៀនត្រូវរៀបចំ៖**

- តារាងបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែ ប្រចាំសប្ដាហ៍ និងតាមមុខវិជ្ជា
- ផែនការបង្រៀនប្រចាំថ្ងៃតាមកាលវិភាគ ប្រចាំសប្ដាហ៍ ផែនការបង្រៀន ៣ខែម្ដងៗ

- **ថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា សាលារៀនត្រូវរៀបចំ៖**
  - រៀបចំផែនការបង្រៀនប្រចាំឆ្នាំតាមកម្រិតថ្នាក់ និងតាមមុខវិជ្ជា
- **ការធ្វើបច្ចុប្បន្នកម្មកិច្ចតែងការបង្រៀនត្រឹមត្រូវនិងបានអនុវត្តទៀងទាត់ សាលារៀនត្រូវរៀបចំ៖**
  - គ្រូបង្រៀនរៀបចំកិច្ចតែងការបង្រៀនប្រចាំថ្ងៃតាមកម្រិតថ្នាក់និងចុះទិដ្ឋាការមុននឹងបង្រៀន ដោយនាយកសាលា
  - ការធ្វើស្វ័យវាយតម្លៃលើការអនុវត្តកិច្ចតែងការបង្រៀន
- **ការប្រជុំវាយតម្លៃការអនុវត្តកម្មវិធីសិក្សាប្រចាំឆមាស និងប្រចាំឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - ផែនការប្រជុំប្រចាំខែ ឆ្នាំ
  - របាយការណ៍ឬកំណត់ហេតុប្រជុំ
  - របាយការណ៍ស្ដីពីការអនុវត្តកម្មវិធីសិក្សាប្រចាំសប្ដាហ៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- **ថ្នាក់រៀនបិទទ្វារ(សរុបថ្នាក់ទាំងអស់គិតជាមធ្យម) សាលារៀនត្រូវរៀបចំ៖**
  - រៀបចំបញ្ជីសម្រង់ថ្នាក់រៀនដែលបិទទ្វារ
  - របាយការណ៍បូកសរុបថ្នាក់រៀនដែលបិទទ្វារ
  - សាលារៀនមានលិខិតអនុញ្ញាតច្បាប់សម្រាប់ថ្នាក់រៀនដែលបិទទ្វារ(កម្រិតសាលានិងថ្នាក់លើ...)
- **ចំនួនថ្ងៃសាលារៀនបិទទ្វារដោយមិនមានការអនុញ្ញត សាលារៀនត្រូវរៀបចំ៖**
  - រៀបចំកំណត់ហេតុពីការផ្អាកដំណើរការបង្រៀននិងរៀន និងកត់ត្រាចំនួនថ្ងៃដែលសាលាបិទទ្វារមិនដំណើរការធ្វើរបាយការណ៍ឱ្យបានត្រឹមត្រូវ។

៣. **សម្ភារៈរៀននិងបង្រៀន៖** សាលារៀននិងថ្នាក់រៀនយកចិត្តទុកដាក់លើដំណើរការបង្រៀននិងរៀនគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់នៅមត្តេយ្យសិក្សា សម្ភារៈសម្រាប់កុមារលេងឱ្យបានគ្រប់គ្រាន់តាមប្រធានបទ។ ដូចនេះ គ្រូបង្រៀនត្រូវចេះផលិតសម្ភារៈបង្រៀននិងរៀនគ្រប់គ្រាន់តាមកម្មវិធីសិក្សា និងឱ្យកុមារលេងបានគ្រប់គ្រាន់ ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសសម្រាប់មត្តេយ្យសិក្សា។

- **ការរៀបចំសម្ភារៈបង្រៀន និងរៀនគ្រប់គ្រាន់តាមកម្មវិធីសិក្សា និងបានឱ្យកុមារមានសម្ភារៈសម្រាប់លេងបានគ្រប់គ្រាន់ សាលារៀនត្រូវរៀបចំ៖**
  - សម្ភារៈសម្រាប់កុមារលេងតាមកម្មវិធីសិក្សា
  - សម្ភារៈផលិតដោយគ្រូ និងកុមារ
  - បញ្ជីស្រង់ឈ្មោះសម្ភារៈដែលបានផលិត

- ○ រៀបចំសម្ភារៈលេងមានចំនួនគ្រប់គ្រាន់សម្រាប់កុមារយ៉ាងតិច៩៥%
- ○ ការរៀបចំជ្រុងថ្នាក់រៀនត្រឹមត្រូវតាមប្រកាសលេខ១៤៥៤ អយក.ប្រក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ ស្តីពីការបើកមត្តេយ្យសិក្សានៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

៤. **ការជួយគាំទ្រសិស្ស៖** សាលារៀនផ្តោតការជួយគាំទ្រកុមារទាំងនៅក្នុងសាលារៀន ថ្នាក់រៀន និងនៅផ្ទះ ដោយគ្រូបង្រៀនត្រូវដាក់ឬបង្កើតកិច្ចការឱ្យកុមារចូលរួមធ្វើសកម្មភាពនៅសាលារៀន ថ្នាក់រៀន និងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀន ចំពោះស្នាដៃកុមារដែលបានធ្វើសកម្មភាពនោះ។ សាលារៀន ថ្នាក់រៀនរៀបចំកិច្ចការសម្រាប់កុមារធ្វើនៅផ្ទះឱ្យបានសមស្រប ដោយមានការចូលរួមជួយពីមាតាបិតា អ្នកអាណាព្យាលកុមារនិងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀនគ្រប់កិច្ចទាំងអស់ត្រឡប់ជូនមាតាបិតា អ្នកអាណាព្យាលកុមារ។

- **ភាគរយកុមារបានធ្វើកិច្ចការនៅសាលារៀន និងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀន សាលារៀនត្រូវរៀបចំ៖**
  - ○ បញ្ជីកត់ត្រាសកម្មភាពកុមារអនុវត្តប្រចាំថ្ងៃនៅសាលារៀន និងថ្នាក់រៀន
  - ○ រៀបចំសន្លឹកកិច្ចការសម្រាប់កុមារអនុវត្តតាមខ្លឹមសារមេរៀននៅសាលារៀន និងថ្នាក់រៀន
- **ភាគរយកុមារបានធ្វើកិច្ចការនៅផ្ទះ និងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀន សាលារៀនត្រូវរៀបចំ៖**
  - ○ បញ្ជីកត់ត្រាសកម្មភាពកុមារអនុវត្តប្រចាំថ្ងៃ នៅសាលារៀន និងថ្នាក់រៀន
  - ○ រៀបចំសន្លឹកកិច្ចការសម្រាប់កុមារអនុវត្តតាមខ្លឹមសារមេរៀន និងឯកភាពពីមាតាបិតា អ្នកអាណាព្យាបាល

៥. **ដំណើរការបណ្ណាល័យ៖** សាលារៀនត្រូវរៀបចំបណ្ណាល័យឱ្យត្រឹមត្រូវនិងដំណើរការជាប្រចាំ ដែលកុមារអាចអនុវត្តសកម្មភាពបាន។

- **ការរៀបចំបណ្ណាល័យត្រឹមត្រូវ និងដំណើរការជាប្រចាំ សាលារៀនត្រូវរៀបចំ៖**
  - ○ ការរៀបចំបណ្ណាល័យ(បន្ទប់ដាច់ដោយឡែក ឬផ្នែកមួយនៃ ជ្រុងទីចាត់ការ ឬថ្នាក់រៀន)
  - ○ ការដាក់តាំងសៀវភៅច្រើនប្រភេទស្របតាមវ័យកុមារ
  - ○ ចាត់តាំងឱ្យមានបណ្ណារក្សជាប្រចាំ
  - ○ បញ្ជីរួម បញ្ជីសារពើភណ្ឌ បញ្ជីខ្ចី សង
  - ○ កាលវិភាគចូលបណ្ណាល័យ
  - ○ បញ្ជីឈ្មោះកុមារចូលបណ្ណាល័យ

៦. **ការធ្វើអធិការកិច្ចផ្ទៃក្នុង៖** សាលារៀនផ្តោតការយកចិត្តទុកដាក់ការធ្វើអធិការកិច្ចផ្ទៃក្នុងលើការបង្រៀននិងរៀន ដោយរៀបចំផែនការអធិការកិច្ចការបង្រៀននិងការគ្រប់គ្រងថ្នាក់រៀនប្រចាំឆ្នាំសិក្សា។ នាយក

សាលារៀន ត្រូវបានចុះសង្កេតការបង្រៀនរបស់គ្រូឆ្លើយតបតាមផែនការ និងធ្វើអធិការកិច្ចផ្ទៃក្នុងយ៉ាងតិច១ដង ក្នុង១ឆ្នាំ ដោយរៀបចំរបាយការណ៍អធិការកិច្ចការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀនរបស់គ្រូបង្រៀនឱ្យបាន ច្បាស់លាស់ផ្តល់ប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀន។

- **ការចុះអធិការកិច្ចសង្កេតការបង្រៀន សាលារៀនត្រូវរៀបចំ៖**
  - ផែនការអធិការកិច្ចការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀនសម្រាប់ឆ្នាំសិក្សា
  - ការចុះសង្កេតការបង្រៀន និងថ្នាក់រៀន
  - របាយការណ៍អធិការកិច្ចការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀនរបស់គ្រូបង្រៀន
  - សាលារៀនមានគ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យទាំងផ្នែកខាងក្នុង និងក្រៅ
  - សាលារៀនមានគ្រូបង្រៀនទទួលបានការធ្វើអធិការកិច្ច ផ្ទៃក្នុងយ៉ាងតិច១ដងក្នុង១ឆ្នាំ

៧. **ការប្រជុំបច្ចេកទេស៖** សាលារៀននិងថ្នាក់រៀននីមួយៗមានការប្រជុំពិនិត្យតាមដានការរៀនសូត្រ ទៀងទាត់តាមផែនការកំណត់។ សាលារៀនត្រូវរៀបចំផែនការការប្រជុំប្រចាំខែ ឆ្នាំ ហើយគ្រប់ដំណើរការកិច្ច ប្រជុំបច្ចេកទេសត្រូវមានរបៀបវារៈ រៀបចំរបាយការណ៍/កំណត់ហេតុអង្គប្រជុំ ដោយភ្ជាប់ជាមួយបញ្ជីវត្តមានអ្នក ចូលរួមប្រជុំ តាមកាលបរិច្ឆេទឱ្យបានជាក់លាក់។

- **ការរៀបចំការប្រជុំបច្ចេកទេសទៀងទាត់តាមផែនការរបស់សាលារៀន សាលារៀនត្រូវរៀបចំ៖**
  - ផែនការការប្រជុំប្រចាំខែ ឆ្នាំ
  - របាយការណ៍/កំណត់ហេតុប្រជុំ បញ្ជីវត្តមាន

៨. **ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា៖** សាលារៀនត្រូវផ្តោតការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោង សិក្សា ដោយបង្កើតកម្មវិធីសិក្សាបន្ថែម ដូចជាកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ នៅសាលាបឋម សិក្សា ឬតំបន់ផ្សេងៗ សកម្មភាពទាំងនេះត្រូវដាក់បញ្ចូលក្នុងផែនការប្រចាំឆ្នាំរបស់សាលាដើម្បីជំរុញការអនុវត្ត ឱ្យមានប្រសិទ្ធភាព។ សាលាត្រូវរៀបចំកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់ជាមួយសាលាមត្តេយ្យសិក្សាដើម្បីបង្កើន ការចូលរួមគាំទ្រសកម្មភាពផ្សេងៗរបស់សាលា ជាពិសេសការអប់រំកុមារ ជាមួយនេះគ្រូបង្រៀនត្រូវបង្កើតការ សិក្សាដកស្រង់បទពិសោធន៍បច្ចេកទេសបង្រៀននិងរៀនតាមរយៈកម្មវិធីប្រឹក្សាគរុកោសល្យជាមួយគ្រូ និងគ្រូ រវាងគ្រូនិងនាយកសាលា ដែលមកពីមត្តេយ្យសិក្សាឯកជន ថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា។ ការ លើកកម្ពស់ចំណាប់អារម្មណ៍របស់មាតាបិតា អាណាព្យាបាល សាលាត្រូវបង្ហាញទេពកោសល្យកុមារ និងមាតា បិតា នៅក្នុងព្រឹត្តការសំខាន់ៗរបស់សាលាប្រចាំឆ្នាំ។

- **ការរៀបចំកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំនៅសាលាបឋមសិក្សា ឬតំបន់ផ្សេងៗ សាលារៀនត្រូវរៀបចំ៖**
  - ផែនការទស្សនកិច្ចសិក្សារបស់កុមារអាយុ៥ឆ្នាំ
  - សាលារៀនមានកិច្ចព្រមព្រៀងរវាងសាលាមត្តេយ្យ និងសាលាបឋមសិក្សា ឬតំបន់ផ្សេងៗ

- បញ្ជីឈ្មោះកុមារអាយុ៥ឆ្នាំ និង មាតាបិតា
- កម្មវិធីប្រជុំផ្សព្វផ្សាយជាមួយមាតាបិតា
- របាយការណ៍ស្តីពីសកម្មភាពទស្សនកិច្ចសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ

- **បង្កើតកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់មត្តេយ្យសិក្សា សាលារៀនត្រូវរៀបចំ៖**
  - ផែនការប្រជុំជាមួយមាតាបិតាប្រចាំឆ្នាំ
  - កំណត់ហេតុប្រជុំ បញ្ជីវត្តមាន
  - រចនាសម្ព័ន្ធកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់មត្តេយ្យសិក្សា
  - ឯកសារម៉ូឌុលកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់មត្តេយ្យសិក្សា
- **កម្មវិធីប្រឹក្សាគរុកោសល្យជាមួយគ្រូសាលាមត្តេយ្យសិក្សា/មត្តេយ្យសិក្សាឯកជន/ថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា សាលារៀនត្រូវរៀបចំ៖**
  - រចនាសម្ព័ន្ធបណ្តាញសាលាក្នុងសហគមន៍
  - ផែនការប្រចាំឆ្នាំការជួយសាលារៀនក្នុងបណ្តាញ
  - សាលារៀនមានកិច្ចព្រមព្រៀងជាមួយសាលារៀន
  - សាលារៀនមានកំណត់ហេតុប្រជុំ បញ្ជីវត្តមាន
- **ការរៀបចំព្រឹត្តិការណ៍បង្ហាញទេពកោសល្យកុមារ និងមាតាបិតា សាលារៀនត្រូវរៀបចំ៖**
  - ផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំ
  - របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ

៩. **ការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌៖** សាលារៀនផ្តោតកាអនុវត្តលើការអប់រំសីលធម៌ និងចរិយាធម៌ ដោយសាលារៀនត្រូវបង្កើតការអនុវត្តកម្មវិធីការអប់រំសីលធម៌ និងចរិយាធម៌ ដើម្បីជួយគាំទ្រការអប់រំកុមារ ក្នុងនោះសាលាត្រូវរៀបចំប្រធានបទសិក្សាដែលទាក់ទងការបណ្តុះទម្លាប់កុមារឱ្យចេះសំពះ ចេះគួរសម ការប្រើពាក្យសំដីសមរម្យជាមួយអ្នកដទៃ។ សាលារៀន និងថ្នាក់រៀន ត្រូវអនុវត្តការអប់រំចិត្តសង្គមកុមារ ការអប់រំផ្លូវចិត្តមាតាបិតា អ្នកអាណាព្យាបាល តាមកម្មវិធីអប់រំបែបពុទ្ធសាសនា។

- **អនុវត្តកម្មវិធីការអប់រំសីលធម៌ និងចរិយាធម៌ (ការអប់រំកុមារពីរបៀបនៃការសំពះ ការគួរសម ការអប់រំឥរិយាបទដេក ដើរ ឈរ អង្គុយ និងការប្រើពាក្យសំដី) សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានអនុវត្តការអប់រំចិត្តសង្គមកុមារ
  - សាលារៀនមានកម្មវិធីអប់រំផ្លូវចិត្តមាតាបិតា អ្នកអាណាព្យាបាល
  - សាលារៀនមានរៀបចំ កម្មវិធីអប់រំបែបពុទ្ធសាសនា។

**ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍**

ស្តង់ដានៃការចូលរួមរបស់សហគមន៍ គឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមត្តេយ្យសិក្សា ដោយផ្តោតលើផលសម្រេចក្នុងឆ្នាំ នៃសកម្មភាពការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន ការចូលរួមរបស់សហគមន៍, និងការគាំទ្ររបស់សហគមន៍។

១. **ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន៖**

សាលារៀនត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដោយមានការចូលរួមពីសំណាក់មាតាបិតា និងសហគមន៍។ ប្រសិនបើមាតាបិតាមិនជួយគាំទ្រនោះទេសាលារៀនក៏មិនជោគជ័យដែរ។ កំណែទម្រង់សាលារៀនកន្លងមកបានបង្ហាញថា សាលារៀនជោគជ័យគឺដោយសារមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍ និងមាតាបិតា អាណាព្យាបាល នៅក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដែលមានដំណើរការ និងមានរបបប្រជុំទៀងទាត់ ព្រមទាំងចូលរួមក្នុងការរៀបចំផែនការកែលម្អសាលារៀន និងមានការប្រជុំទៀងទាត់។ នាយកនិងនាយករងនឹងត្រូវទទួលការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំពីគណៈកម្មការគ្រប់គ្រងសាលារៀន។ សាលារៀនត្រូវរៀបចំការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន៖

- **គណៈកម្មការគ្រប់គ្រងសាលារៀនបានរៀបចំកិច្ចប្រជុំ តាមផែនការកំណត់ សាលារៀនត្រូវរៀបចំ៖**
  - o របាយការណ៍ប្រជុំស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន
  - o លិខិតបង្គាប់ការគណៈកម្មការគ្រប់គ្រងសាលារៀនមានការទទួលស្គាល់តាមការណែនាំ
  - o រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចច្បាស់លាស់តាមការណែនាំ
  - o របាយការណ៍ប្រជុំ និងរបាយការណ៍វឌ្ឍនភាពតាមការណែនាំ
  - o របាយការណ៍បង្ហាញអំពីការគាំទ្រឱ្យសាលារៀនមានការអភិវឌ្ឍទាំងលទ្ធផលសិក្សារបស់កុមារ និងការកែលម្អបរិស្ថានសាលារៀន។

២. **ការចូលរួមរបស់សហគមន៍៖** ព័ត៌មាននានាត្រូវបានអនុម័តដោយ គ.គ.ស. និងបិទផ្សាយជាសាធារណៈ, សហគមន៍បានចូលរួមប្រជុំទៀងទាត់តាមផែនការ, សហគមន៍ចូលរួមរៀបចំបរិស្ថាន បៃតង អនាម័យ អគារសិក្សា បន្ទប់រៀន សម្ភារៈ និងបរិក្ខារសិក្សា, សាលារៀនមាន កិច្ចសហប្រតិបត្តិការភាពជាដៃគូវិនិយោគជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ, មាតាបិតាឬអ្នកអាណាព្យាបាលចូលរួមអនុវត្តកម្មវិធីអប់រំទៀងទាត់,។

- **មាតាបិតា អ្នកអាណាព្យាបាលចូលរួមប្រជុំតាមការអញ្ជើញរបស់នាយកសាលា សាលារៀនត្រូវរៀបចំ៖**
  - o ផែនការប្រជុំនិងអនុវត្តឱ្យបានទៀងទាត់ដោយមានការចូលរួមពីមាតាបិតា អ្នកអាណាព្យាបាល រដ្ឋបាលឃុំ សង្កាត់ និងសហគមន៍
  - o របាយការណ៍ស្តីពីសហគមន៍បានចូលរួមប្រជុំទៀងទាត់តាមផែនការ
  - o របាយការណ៍សកម្មភាពសហគមន៍ចូលរួមរៀបចំបរិស្ថានបៃតង អនាម័យ អគារសិក្សា

បន្ទប់រៀន សង្ហារិម និងបរិក្ខារសិក្សាបានថែរក្សា និងពង្រីកបន្ថែមតាមបែបបច្ចេកវិទ្យា។

- **សកម្មភាពកិច្ចសហការបច្ចេកទេសជាមួយភាពជាដៃគូវិនិយោគរវាងវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ លើការរៀបចំអាហារសម្រន់ ឬអាហារតាមសាលារៀន កន្លែងក្មេងលេង សាលារៀនត្រូវរៀបចំ៖**
    - សាលារៀនមានកិច្ចព្រមព្រៀងជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ
    - របាយការណ៍ស្តីពីបូកសរុបលទ្ធផលនៃសកម្មភាពកិច្ចសហការបច្ចេកទេសជាមួយភាពជាដៃគូវិនិយោគ។

៣. **ការគាំទ្ររបស់សហគមន៍៖** មាតាបិតា អ្នកអាណាព្យាបាល រដ្ឋបាលឃុំ សង្កាត់ និងសហគមន៍បានចូលរួមជួយគាំទ្រមូលនិធិ និងកិច្ចដំណើរការគ្រប់គ្រងសាលារៀនជាការផ្តល់ធាតុចូលដល់សាលារៀន ការរក្សាមូលដ្ឋានឱ្យនៅតែរឹងមាំដោយក្នុងនោះបានចូលរួមធនធានពីសហគមន៍ដោយស្ម័គ្រចិត្តជាដើមជាជំនួយដល់កុមារឱ្យមានការរីកចម្រើនលើការសិក្សា ៖

- **សហគមន៍បានចូលរួមជួយគាំទ្រ មូលនិធិដំណើរការសាលារៀន និងសកម្មភាពរបស់សាលារៀន សាលារៀនត្រូវរៀបចំ៖**
    - បញ្ជីរបាយការណ៍ចំណូលចំណាយថវិកា
    - បញ្ជីរបាយការណ៍សម្ភារៈ
    - របាយការណ៍សកម្មភាពសកម្មភាពរបស់សហគមន៍ចូលរួមជួយរៀបចំអានាម័យ និងការថែទាំបរិស្ថាន
    - របាយការណ៍សកម្មភាពរបស់សហគមន៍ចូលរួមជួយរៀបចំសន្តិសុខ និងសណ្តាប់សាលារៀន
    - របាយការណ៍បូកសរុបការគាំទ្រសាលារៀនរបស់សហគមន៍។

## ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន

ស្តង់ដានៃដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន គឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមត្តេយ្យសិក្ស ដោយផ្តោតលើផលសម្រេចក្នុងឆ្នាំ នៃសកម្មភាពសាលារៀនដែលមានលក្ខណៈល្អប្រសើរជាសាលាមួយដែលមានការរីកចម្រើន មានការអភិវឌ្ឍលើគ្រប់ផ្នែកដោយឆ្លើយតបដល់លទ្ធផលសិក្សារបស់កុមារបានស្របតាមកម្មវិធីសិក្សាបាន គឺអាស្រ័យលើការគ្រប់គ្រងទូទៅនិងរដ្ឋបាល ការរៀបចំផែនការអភិវឌ្ឍសាលារៀន ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក វង្វាយតម្លៃលទ្ធផលសិក្សា ការលើកកម្ពស់សុខភាពសិក្សា និងអាហារូបត្ថម្ភ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ។

សាលារៀនមានដំណើរការល្អ អាស្រ័យលើការរៀបចំផែនការសកម្មភាពអនុវត្តច្បាស់លាស់ រយៈពេលមធ្យមនិងប្រចាំឆ្នាំ ព្រមទាំងផ្តោតលើផលសម្រេចនៃការអប់រំនិងឈរលើមូលដ្ឋាននៃការវាយតម្លៃលទ្ធផលសិក្សារបស់កុមារត្រឹមត្រូវតាមកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា។ លទ្ធផលវាយតម្លៃការសិក្សារបស់កុមារ ត្រូវបានយកមកប្រើប្រាស់ដើម្បីជួយដល់ការសិក្សារៀនសូត្ររបស់កុមារអភិវឌ្ឍន៍យឺត។ សាលារៀនត្រូវធ្វើអធិការកិច្ចផ្ទៃក្នុងនិងការប្រជុំបច្ចេកទេសជាទៀងទាត់តាមផែនការ គ្រូបង្រៀន និងនាយកសាលាត្រូវបានបញ្ជូនឱ្យចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ។

សាលារៀនត្រូវអនុវត្តការងាររដ្ឋបាលដែលមានប្រសិទ្ធភាព ដោយត្រូវយកចិត្តទុកដាក់លើការគ្រប់គ្រងគ្រូបង្រៀន ដូចជាបញ្ហាលើស ខ្វះគ្រូ គ្រូបង្រៀនតាមមុខវិជ្ជា ការរៀបចំផែនការដំណើរការសាលារៀន ការផ្តល់សម្ភារៈឧបទេស រួមទាំងវិធីសាស្ត្របង្រៀន។

១. **ការគ្រប់គ្រងទូទៅនិងរដ្ឋបាល** ៖ សាលារៀនមានរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងត្រឹមត្រូវ, សាលារៀនមានប្រព័ន្ធគ្រប់គ្រប់ទិន្នន័យស្ថិតិអប់រំច្បាស់លាស់(បុគ្គលិក កុមារ និងសារពើភណ្ឌ)សាលារៀនប្រើប្រាស់ App សម្រាប់ប្រព័ន្ធ គ្រប់គ្រងទិន្នន័យសាលារៀនដែលមានគ្រូលើស ខ្វះបានថយចុះ ត្រូវបានដោះស្រាយ។

- **ការរៀបចំការគ្រប់គ្រងទូទៅនិងរដ្ឋបាល សាលារៀនត្រូវរៀបចំ៖**
  - ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងត្រឹមត្រូវ
  - ចំណាត់តាំងភារកិច្ចនៃគណៈគ្រប់គ្រង
  - បំណែងចែកតួនាទីភារកិច្ចទទួលខុសត្រូវរបស់បុគ្គលិក
  - ស្ថិតិបុគ្គលិកអប់រំ និងកុមារ
  - បញ្ជីសម្ភារៈ និងសារពើភ័ណ្ឌ
- **ការប្រើប្រាស់ App សម្រាប់គ្រប់គ្រងទិន្នន័យ សាលារៀន សាលារៀនត្រូវរៀបចំ៖**
  - ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) និងប្រើប្រាស់ជាប្រចាំ
  - ដំណើរការ App សម្រាប់គ្រប់គ្រងទិន្នន័យរបស់សាលារៀន
  - ការគ្រប់គ្រងទិន្នន័យនិងអាចទាញយកជារបាយការណ៍តាមតម្រូវការ
  - បញ្ចូលទិន្នន័យដែលបានបញ្ចូលទៅក្នុងប្រព័ន្ធ ឬ App
  - ផ្សព្វផ្សាយទិន្នន័យរបស់សាលារៀនដល់សាធារណៈជន ជាពិសេសមាតាបិតា អ្នកអាណាព្យាបាល សហគមន៍ និងអាជ្ញាធរដែនដី
- **គ្រូបង្រៀនខ្វះត្រូវបានដោះស្រាយ សាលារៀនត្រូវរៀបចំ៖**
  - បញ្ជីគណៈគ្រប់គ្រង និងគ្រូបង្រៀនលើស ឬ ខ្វះ
  - ផែនការតម្រូវការបុគ្គលិក
- **ការរៀបចំកម្មវិធីប្រជុំប្រចាំខែ ត្រីមាស និងឆមាសត្រឹមត្រូវ សាលារៀនត្រូវរៀបចំ៖**
  - កម្មវិធីសកម្មភាពការងារប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់សាលារៀន
  - របាយការណ៍/កំណត់ហេតុប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- **ការរៀបចំរបាយការណ៍ត្រឹមត្រូវតាមការណែនាំ សាលារៀនត្រូវរៀបចំ៖**
  - របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំ
  - របាយការណ៍សកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

២. **ការរៀបចំផែនការអភិវឌ្ឍសាលារៀន៖** សាលារៀនបានកំណត់ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះ, សាលារៀនមានរបាយការណ៍ប្រចាំឆ្នាំត្រឹមត្រូវ, ផែនការសាលារៀន(៥ឆ្នាំ ៣ឆ្នាំ និង១ឆ្នាំ)បានរៀបចំតាមការណែនាំ

- **សាលារៀនរៀបចំផែនការ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ និង សកម្មភាពគន្លឹះ
  - ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ៥ឆ្នាំ
  - ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ
  - ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការថវិកាប្រចាំឆ្នាំ
  - ផែនការកែលម្អសាលារៀនបានអនុម័តជាផ្លូវការ

៣. **ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក៖** សាលារៀនត្រូវផ្ដោតការយកចិត្តទុកដាក់លើការបំពេញការងាររបស់បុគ្គលិកដោយនាយករងនិងគ្រូបង្រៀនត្រូវចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំជាមួយនាយកសាលា នាយកសាលាត្រូវចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំជាមួយគណៈគ្រប់គ្រងសាលារៀន។ សាលារៀន ត្រូវធ្វើការតម្លៃការបំពេញការងាររបស់បុគ្គលិក នាយកសាលាត្រូវវាយតម្លៃនាយករង និងគ្រូបង្រៀន និងមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសាលារៀន នាយកសាលារៀនត្រូវវាយតម្លៃការបំពេញការងារដោយគណៈគ្រប់គ្រងសាលារៀន ។

- **គ្រូបង្រៀន និងបុគ្គលិកអប់រំបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - រៀបចំប្រជុំផ្សព្វផ្សាយអំពីគោលការណ៍នៃការចុះកិច្ចព្រមព្រៀងរវាងនាយកសាលានិងគ្រូបង្រៀន ក្រោមការអនុម័តពី ប្រធាន គ.គ.ស.
  - កិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំរវាងនាយកសាលារៀន និងគ្រូបង្រៀននិងបុគ្គលិកអប់រំ
  - កិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំរវាងគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រង
  - ប្រព័ន្ធវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀនប្រចាំឆ្នាំ
  - កម្មវិធីលើកទឹកចិត្ត(ការលើកសរសើរទស្សនកិច្ចសិក្សាសម្រាប់គ្រូ ទៅសាលាផ្សេងក្នុងឆ្នាំសិក្សា)
- **នាយកសាលានិងនាយករងបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ សាលារៀនត្រូវរៀបចំ៖**
  - កិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំរវាងគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រង
  - ប្រព័ន្ធវាយតម្លៃការអនុវត្តការងាររបស់គណៈគ្រប់គ្រងសាលារៀនប្រចាំឆ្នាំ
  - កម្មវិធីលើកទឹកចិត្ត(ការលើកសរសើរទស្សនកិច្ចសិក្សាសម្រាប់គណៈគ្រប់គ្រងសាលារៀន

ទៅសាលាផ្សេងក្នុងឆ្នាំសិក្សា)

៤. **វាយតម្លៃលទ្ធផលសិក្សា៖** សាលារៀនបានរៀបចំការវាយតម្លៃលទ្ធផលសិក្សាកុមារតាមកម្មវិធីសិក្សាតាមកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ស្របតាមគោលការណ៍ណែនាំជាធរមាន លទ្ធផលនៃការវាយតម្លៃលទ្ធផលសិក្សារបស់ជាកម្មវត្ថុ នៃការជួយកុមារដែលមានការអភិវឌ្ឍយឺត។

- **ការអនុវត្តការវាយតម្លៃលទ្ធផល សិក្សារបស់សិស្សតាមកម្មវិធីសិក្សា សាលារៀនត្រូវរៀបចំ៖**
    - o របៀបរបបវាយតម្លៃលទ្ធផលសិក្សារបស់កុមារតាមកម្មវិធីសិក្សា
    - o ផែនការជួយកុមារអភិវឌ្ឍន៍យឺត
    - o បញ្ជីវាយតម្លៃការអភិវឌ្ឍសមត្ថភាពកុមារតាមកម្រិតថ្នាក់
    - o របាយការណ៍ការអនុវត្តការវាយតម្លៃលទ្ធផលសិក្សារបស់កុមារ
    - o បញ្ជីលទ្ធផលនៃការវាយតម្លៃការអភិវឌ្ឍសមត្ថភាពរបស់កុមារ

៥. **ការលើកកម្ពស់សុខភាពសិក្សានិងអាហារូបត្ថម្ភរបស់សិស្ស៖** សាលារៀនផ្ដោតការយកចិត្តទុកដាក់អនុវត្តសកម្មភាពការលើកកម្ពស់សុខភាពសិក្សានិងអាហារូបត្ថម្ភរបស់កុមារ ដោយសាលារៀនត្រូវណែនាំគ្រូបង្រៀនពីសេវាថែទាំសុខភាពបឋម ជំរុញសកម្មភាពពិនិត្យសុខភាពកុមារឱ្យបានទៀងទាត់ ពង្រឹងការលើកកម្ពស់ទឹកស្អាត ការអនុវត្តអនាម័យជាប្រចាំ និងសុវត្ថិភាពចំណីអាហារប្រកបដោយសុខភាព។ សាលារៀនត្រូវអនុវត្តកម្មវិធីអប់រំសុខភាព រក្សាបរិស្ថានក្នុង និងក្រៅថ្នាក់រៀនឱ្យស្អាត មានសោភ័ណ្ឌភាពបៃតងជានិច្ច ប្រកបដោយមេត្រីភាព ធានានិងរក្សាបានសន្តិសុខសណ្ដាប់ធ្នាប់ ព្រមផ្ដល់ការការពារកុមារឱ្យរួចផុតពីគ្រោះមហន្តរាយនានា និងបង្កលក្ខណៈសម្បត្តិសមស្របក្នុងការផ្ដល់ឱកាសដល់កុមារបានចូលរួមអនុវត្តសកម្មភាពអប់រំកាយនិងកីឡាសម្រាប់មត្តេយ្យសិក្សា។

- **ការលើកកម្ពស់សេវាថែទាំសុខភាពបឋម សាលារៀនត្រូវរៀបចំ៖**
    - o គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាមានសមាសភាពតួនាទីភារកិច្ចច្បាស់លាស់ និងមាននីត្យានុកូល
    - o បរិក្ខារនិងសម្ភារៈសង្គ្រោះបឋម
    - o របាយការណ៍ស្ដីពីការផ្ដល់ថ្នាំបង្ការតាមកម្មវិធីជាតិផ្ដល់ថ្នាំបង្ការ ឬថ្នាំទម្លាក់ដង្កូវព្រូន
    - o បន្ទប់សុខភាពនិងសម្ភារៈប្រើប្រាស់ជាមូលដ្ឋានចាំបាច់
    - o យន្តការគ្រប់គ្រងកិច្ចដំណើរការបន្ទប់សុខភាព
- **ការពិនិត្យសុខភាពសិស្ស សាលារៀនត្រូវរៀបចំ៖**
    - o ផែនការពិនិត្យសុខភាពកុមារ
    - o សៀវភៅតាមដានសុខភាពកុមារ
    - o របាយការណ៍ទិន្នន័យស្ដីពីការពិនិត្យសុខភាពកុមារ ឬការផ្ដល់សេវាសុខភាពផ្សេងៗ

- របាយការណ៍ស្ដីពីកិច្ចអន្តរាគមន៍ចំពោះកុមារដែលមានបញ្ហាសុខភាពមិនល្អបានទៅទទួលសេវាគាំទ្រ

- **ការលើកកម្ពស់ទឹកស្អាត និងអនាម័យ សាលារៀនត្រូវរៀនចំ៖**
  - បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងបណ្ដាញទឹកស្អាត
  - កម្មវិធីការគ្រប់គ្រងអនាម័យ
  - បណ្ដាញទឹកស្អាតសម្រាប់ទទួលទានរបស់គ្រូ និងកុមារ
  - កាលវិភាគស្ដីពីការលាងសម្អាតដៃនិងដុសសម្អាតធ្មេញជាក្រុមសម្រាប់កុមារទាំងអស់

- **ការលើកកម្ពស់សុវត្ថិភាពចំណីអាហារប្រកបដោយសុខភាព សាលារៀនត្រូវរៀបចំ៖**
  - ការបិទផ្សាយគោលការណ៍ណែនាំស្ដីពីការលើកកម្ពស់ សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព
  - អ្នកលក់មានកិច្ចសន្យាច្បាស់លាស់ជាមួយនាយកសាលា ឬអាជ្ញាធរមានសមត្ថកិច្ច
  - យន្តការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនិងអាហារ ប្រកបដោយសុខភាព

- **ការអនុវត្តកម្មវិធីអប់រំសុខភាព សាលារៀនត្រូវរៀបចំ៖**
  - ផែនការបង្រៀន និងកាលវិភាគអប់រំសុខភាព
  - សៀវភៅតាមដានការបង្រៀនមុខវិជ្ជាអប់រំសុខភាព
  - របាយការណ៍ពីការអប់រំផ្សព្វផ្សាយពីសារសុខភាពផ្សេងៗគ្រប់រូបភាព
  - របាយការណ៍លទ្ធផលអប់រំសុខភាព

- **ការលើកកម្ពស់បរិស្ថានស្អាត បៃតង សុវត្ថិភាព អនាម័យ និងមេត្រីភាព សាលារៀនត្រូវរៀបចំ៖**
  - ធុងសំរាមបានរៀបចំស្របតាមលក្ខណៈបច្ចេកទេស ឬមានឡដុតសំរាមតាមស្តង់ដាបច្ចេកទេស
  - សួនផ្កាលម្អ រុក្ខជាតិ ដើមឈើ សួនបន្លែវិលជុំ សួនជីវៈចម្រុះ
  - យន្តការត្រួតពិនិត្យនិងការសម្អាតអនាម័យ
  - សាលារៀនគ្មានប្រើប្រាស់ថង់ប្លាស្ទីក

- **ការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ ការការពារកុមារ ការបង្ការគ្រោះមហន្តរាយនានាសាលារៀនត្រូវរៀបចំ៖**
  - របង ទ្វារចេញចូលត្រឹមត្រូវ
  - ប្រព័ន្ធកិច្ចការពារកុមារ ការរៀបចំយន្តការសណ្ដាប់ធ្នាប់ រក្សាសុវត្ថិភាព ការដាក់ស្លាកសញ្ញាចរាចរណ៍ ការបង្ការការលង់ទឹក សម្ភារៈបរិក្ខារជូនដំណឹងពីសញ្ញាគ្រោះថ្នាក់ បំពង់ពន្លត់អគ្គីភ័យ

- **ការអនុវត្តសកម្មភាពអប់រំកាយនិងកីឡា សាលារៀនត្រូវរៀបចំ៖**
  - ទីធ្លាសម្រាប់ធ្វើសកម្មភាពអប់រំកាយនិងកីឡា
  - តារាងវាយតម្លៃលទ្ធផលការសិក្សារបស់កុមារពីអប់រំកាយនិងកីឡា

៦. **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ៖** សាលារៀនផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍហេដ្ឋារចនា សម្ព័ន្ធអប់រំដោយសាលារៀនត្រូវរៀបចំសួនកុមារ និងសម្ភារៈសម្រាប់កុមារលេងដោយសេរី និងមានសុវត្ថិភាព។ សាលារៀនត្រូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំល្អប្រសើរ ដើម្បីគុណភាព និងប្រសិទ្ធភាពនៃការបង្រៀននិងរៀន។

- **ការរៀបចំសួនកុមារនិងសម្ភារៈសម្រាប់កុមារលេងដោយសេរីនិងមានសុវត្ថិភាពសាលារៀនត្រូវ៖**
  - របងសុវត្ថិភាព
  - ស្លាកឈ្មោះ
  - សម្ភារៈល្បែង
  - ការប្រើប្រាស់ពណ៌
  - ការរៀបចំស្លាកសញ្ញាសម្គាល់
- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំល្អប្រសើរ សាលារៀនត្រូវរៀបចំ៖**
  - បណ្តាញអគ្គិសនីបំពាក់អ៊ិនធើណេត
  - បន្ទប់សុខភាព
  - អាហារដ្ឋាន និងបង្គន់អនាម័យ
  - បន្ទប់កុំព្យូទ័រ និងបណ្ណាល័យ
  - បន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប( LCD, Smart TV, Smart Boad )

## ស្តង់ដាទី៩ ៖ គណនេយ្យភាពរបស់សាលារៀន

ស្តង់ដានៃគណនេយ្យភាពរបស់សាលារៀនគឺជាខ្នាតគំរូសម្រាប់កំណត់ពីស្ថានភាពសាលាមត្តេយ្យសិក្សា ដោយផ្តោតលើផលសម្រេចក្នុងឆ្នាំ ដោយឆ្លុះបញ្ចាំងពីសកម្មភាពក្នុងការរៀបចំវេទិកាសាធារណៈជាមួយមាតាបិតា អ្នកអាណាព្យាបាល ដើម្បីផ្សព្វផ្សាយព័ត៌មានសមិទ្ធផល និងបញ្ហាប្រឈមទាំងឡាយរបស់សាលា សំដៅស្វែងរក ដំណោះស្រាយ ព្រមទាំងការគាំទ្រលើផ្នែកបច្ចេកទេស និងធនធានសម្ភារៈពីគ្រប់ភាគីពាក់ព័ន្ធ។

ក្នុងការរក្សាបាននូវគណនេយ្យភាពសាលារៀនត្រូវកំណត់គោលដៅ សូចនាករផលសម្រេចដែលអាច វាស់វែង និងកំណត់វិធានការដោះស្រាយប្រសិនបើមិនសម្រេចបានតាមសូចនាករ។ របាយការណ៍គឺជាផ្នែកមួយ ដែលសាលារៀនត្រូវមាន និងផ្សព្វផ្សាយជាសាធារណៈឱ្យបានទៀងទាត់ ដើម្បីបង្កើនភាពជឿទុកចិត្តពីមាតា បិតា អ្នកអាណាព្យាបាល និងសហគមន៍។ នាយកសាលា ត្រូវពង្រឹងការបំពេញការងាររបស់គ្រូបង្រៀនឱ្យគោរព តាមក្រមសីលធម៌វិជ្ជាជីវៈបង្រៀនគ្រូ អនុវត្តការបង្រៀនឱ្យបានទៀងទាត់គ្រប់ម៉ោងតាមកម្មវិធីសិក្សាកំណត់។ នាយកសាលាត្រូវផ្តល់ឱកាសដល់គ្រូបង្រៀនក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ ជំរុញលើកទឹកចិត្តគ្រូ

បង្រៀនឱ្យចូលសកម្មភាពជាមួយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការចុះពិនិត្យសាលារៀនដើម្បីទទួលការគាំទ្រ និងផ្តល់ការហ្វឹកហាត់បច្ចេកទេសថ្មីបន្ថែម។

១. **វេទិកាសាធារណៈ**៖ សាលារៀនផ្តោតជាសំខាន់លើការរៀបចំវេទិកាសាធារណៈ ដោយសាលារៀនត្រូវបង្កើតកម្មវិធីជួបប្រជុំមាតាបិតា អ្នកអាណាព្យាបាល(ទៅតាមប្រធានបទ ដូចជាការណែនាំអំពីការកាត់បន្ថយនិងលុបបំបាត់អំពីហិង្សនៅក្នុងគ្រួសារនិងសាលារៀន, ការជំរុញការសិក្សារៀនសូត្រ, ការលើកកម្ពស់អាហារូបត្ថម្ភ, ការអប់រំអំពីគ្រឿងញៀន ច្បាប់ចរាចរ និងការងារផ្សេងៗទៀត)។

- **រៀបចំកម្មវិធីជួបជុំជាមួយមាតាបិតា អ្នកអាណាព្យាបាលកុមារ និងសហគមន៍ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានផែនការសកម្មភាពប្រចាំឆ្នាំ
  - សាលារៀនមានរបាយការណ៍លទ្ធផល
  - សាលារៀនមានបញ្ជីវត្តមានអ្នកចូលរួម

២. **ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ**៖ សាលារៀនផ្តោតការយកចិត្តទុកដាក់ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដោយការបង្ហាញលទ្ធផលសិក្សារបស់កុមារ ផ្សព្វផ្សាយសកម្មភាពប្រតិបត្តិនិងសមិទ្ធផលជាសាធារណៈ, ទិន្នន័យវាយតម្លៃលទ្ធផលសិក្សារបស់កុមារ ដែលត្រូវបានអនុម័តនិងបិទផ្សាយ។

- **ផ្សព្វផ្សាយព័ត៌មានជាសាធារណៈតាមការណែនាំ សាលារៀនត្រូវរៀបចំ៖**
  - ផែនការសាលារៀន
  - បិទផ្សាយឯកសារសកម្មភាព ឬស្នាដៃកុមារ និងព័ត៌មានផ្សេងៗ
  - ផ្តល់របាយការណ៍លទ្ធផលកុមារដែលមានការអភិវឌ្ឍឃើតឱ្យមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍
  - ផ្សព្វផ្សាយពីសកម្មភាពការងាររបស់សាលារៀន ដើម្បីកៀរគរការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍
  - របាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ

៣. **ការទទួលបានការគាំទ្រពីថ្នាក់ជាតិ**៖ សាលារៀនត្រូវការការគាំទ្រពីថ្នាក់ជាតិ ដោយនាយកសាលានិងនាយករង ត្រូវបានទទួលការហ្វឹកហាត់អនុវត្តការគ្រប់គ្រងតាមសាលារៀន គ្រូបង្រៀនបានទទួលការបំប៉នសមត្ថភាពលើវិធីសាស្ត្របង្រៀនសម្រាប់មត្តេយ្យសិក្សា តាមរយៈក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចុះពិនិត្យតាមដាន និងផ្តល់ការគាំទ្រតាមផែនការ។ នាយកសាលានិងនាយករងបានទទួលការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូ សាលារៀនទទួលការចុះជួយបច្ចេកទេសពីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា។

- **នាយក និងនាយករងបានទទួលការហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធីសាលារៀនគំរូ សាលារៀនត្រូវរៀបចំ៖**
  - បញ្ជីរាយនាមនាយក នាយករងទទួលការហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធីសាលារៀនគំរូ

- របាយការណ៍លទ្ធផលនៃការអនុវត្តការងារ។

- **ការចុះពិនិត្យតាមដាន និងផ្តល់ការគាំទ្រពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សាលារៀនត្រូវរៀបចំ៖**
  - សាលារៀនមានគ្រូបង្រៀន ក្រុមបច្ចេកទេស និងគណៈគ្រប់គ្រងសាលារៀន មានបញ្ជីកត់ត្រាជំនួយបច្ចេកទេសពីថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ
  - សាលារៀនមានតារាងកត់ត្រាទិន្នន័យព័ត៌មាន និងផ្តល់យោបល់ពីការជួយសម្រាប់សាលារៀនពីថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធ

## ៧. ការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

### ៧.១. ឧបករណ៍វាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ នឹងត្រូវបានប្រែក្លាយជាឧបករណ៍សម្រាប់វាយតម្លៃសាលាមត្តេយ្យសិក្សាដែលមានភាគីពាក់ព័ន្ធ ដូចជាការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ព្រមទាំងគ្រប់ភាគីពាក់ព័ន្ធ អាចយកទៅប្រើប្រាស់ក្នុងការវាយតម្លៃ ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ។ ឧបករណ៍វាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូជាឧបសម្ព័ន្ធនៃឯកសារនេះ។

*ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ មិនសំដៅទៅរកការដាក់វិន័យ ឬទណ្ឌកម្ម ចំពោះនាយក គ្រូបង្រៀន សិស្ស សហគមន៍ ឬអ្នកពាក់ព័ន្ធដែលបំពេញការងារមិនបានទាន់ឆ្លើយតបស្តង់ដាទេ។ ប៉ុន្តែស្តង់ដាសាលាមត្តេយ្យសិក្សាគំរូជាផ្លាស់ ឬមគ្គុទេសក៍ដឹកនាំអ្នកពាក់ព័ន្ធនានាឈានទៅដល់ ឬ លើសស្តង់ដា។ ប្រសិនបើមានស្តង់ដាណាមួយពុំទាន់សម្រេចនោះអ្នកពាក់ព័ន្ធមាន ឱកាសវាយតម្លៃស្ថានភាព និងកសាងមធ្យោបាយ ដើម្បីធ្វើឱ្យសម្រេច ឬលើសកម្រិតស្តង់ដានាពេលអនាគត។*

*"ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ និងការវាយតម្លៃជាមធ្យោបាយ រីឯសាលាមត្តេយ្យសិក្សាជាគោលដៅក្នុងការកែលម្អ"។*

### ៧.២. របបនៃការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

ដើម្បីជានាបានថា ការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ លទ្ធផលអាចទទួលយកបានត្រូវអនុវត្តដូចខាងក្រោម៖

គណៈគ្រប់គ្រងសាលាមត្តេយ្យសិក្សា ត្រូវធ្វើស្វ័យវាយតម្លៃជារៀយៗក្នុង ពេលដំណើរការបំពេញការងារតាមរយៈការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ឬតាមប្រព័ន្ធផ្សេងទៀត តាមស្ថានភាពជាក់ស្តែងរបស់សាលារៀននីមួយៗ ដោយមានការជួយសម្របសម្រួលការងារបច្ចេកទេសពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការបូកសរុបលទ្ធផល និងវាយតម្លៃសាលាមត្តេយ្យសិក្សា ដើម្បីបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា នៃរដ្ឋបាលរាជធានី ខេត្ត។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវត្រួតពិនិត្យលើការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូដើម្បីបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានអប់រំកុមារតូច)។ នាយកដ្ឋានអប់រំកុមារតូច ដែលជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំវាយតម្លៃពិនិត្យនិងវាយតម្លៃសាលាមត្តេយ្យសិក្សាតាមយន្តការនិងនីតិវិធីជាធរមាន។

ចំពោះបែបបទនិងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ នឹងមានសេចក្តីអធិប្បាយក្នុងចំណុចខាងក្រោមនៃឯកសារនេះ។ ក្របខ័ណ្ឌពេលវេលានៃដំណើរការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូប្រចាំឆ្នាំ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាតាមជាក់ស្តែង។

### ៧.៣. គំរូនៃការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

ដើម្បីមានមូលដ្ឋានក្នុងការអនុវត្តការវាយតម្លៃសាលាមត្តេយ្យសិក្សាអាចប្រព្រឹត្តទៅបានប្រកបដោយសង្គតិភាព និងលទ្ធផលជឿទុកចិត្តបាន គ្រប់មុខសញ្ញាអ្នកពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមគំរូនៃការវាយតម្លៃសាលាមត្តេយ្យសិក្សាដូចខាងក្រោម៖

| ល.រ | សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| ស្តង់ដាទី៨ ឧត្តមានុភាពរបស់សាលារៀន | | | | |
| ១ | វេទិកាសាធារណៈ | | | |
| ១.១ | សាលារៀនរៀបចំកម្មវិធីជួបជុំជាមួយមាតាបិតា អ្នកអាណាព្យាបាលកុមារ និងសហគមន៍ | - សាលារៀនមានផែនការប្រចាំឆ្នាំ<br>- សាលារៀនមានរបាយការណ៍លទ្ធផល<br>- សាលារៀនមានបញ្ជីវត្តមានអ្នកចូលរួម | មានគ្រប់ និងត្រឹមត្រូវ | ៥ |
| ២ | ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ | | | |
| ២.១ | សាលារៀនបានផ្សព្វផ្សាយព័ត៌មានជាសាធារណៈតាមការណែនាំ | - សាលារៀនមានផែនការសាលារៀន<br>- សាលារៀនមានបិទផ្សាយឯកសារ សកម្មភាព ឬស្នាដៃកុមារ និងព័ត៌មានផ្សេងៗ<br>- សាលារៀនបានផ្តល់របាយការណ៍លទ្ធផលនៃការអភិវឌ្ឍរបស់កុមារយ៉ាងឱ្យមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍<br>- សាលារៀនមានសកម្មភាពការងាររបស់សាលារៀន<br>- សាលារៀនមានរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ | មានគ្រប់ និងត្រឹមត្រូវ | ៥ |

| | | | | |
|---|---|---|---|---|
| ៣ | ការទទួលបានការគាំទ្រពីថ្នាក់ជាតិ | | | |
| ៣.១ | ចំនួននាយក និងនាយករងបានទទួលការហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធីសាលារៀនគំរូ | - សាលារៀនមានបញ្ជីរាយនាមនាយក នាយករងទទួលការហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធីសាលារៀនគំរូ<br>- សាលារៀនមានរបាយការណ៍លទ្ធផលនៃការអនុវត្ត | មានតិចតួច | ២ |
| ៣.២ | សាលារៀនបានទទួលការចុះពិនិត្យតាមដាន និងផ្តល់ការគាំទ្រពីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | - សាលារៀនមានគ្រូបង្រៀន ក្រុមបច្ចេកទេស និងគណៈគ្រប់គ្រងសាលារៀនមានបញ្ជីកត់ត្រាជំនួយបច្ចេកទេសពីថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ<br>- សាលារៀនមានតារាងកត់ត្រាទិន្នន័យព័ត៌មាន និងផ្តល់យោបល់ពីការជួយសម្រាប់សាលារៀនពីថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធ | មានគ្រប់ | ៤ |
| សរុបពិន្ទុ | | | | ១៦ |

**វិធីគណនា**

- ស្តង់ដាទី៥ មានសូចនាករចំនួន២០ពិន្ទុ
- ក្នុងចំណោមសូចនាករទាំង៤ អនុវត្តបាន ១៦ពិន្ទុ

ដូចនេះ វិធីគណនាជាភាគរយគឺ៖ ចំនួនសូចនាករដែលអនុវត្តបាន១៦ពិន្ទុ ចែកនឹងចំនួនសូចនាករសរុប២០ពិន្ទុ ហើយគុណនឹង១០០។

ផ្អែកតាមការវាយតម្លៃខាងលើលទ្ធផលបានបង្ហាញឱ្យឃើញថា សាលាមត្តេយ្យសិក្សានោះបានអនុវត្តសម្រេច១៦ពិន្ទុ លើ២០ពិន្ទុ ក្នុងចំណោមសូចនាករទាំង៤ នៃស្តង់ដាទី៥ ស្មើនឹង ៨០% មានន័យថា ទទួលបានជាសាលាមត្តេយ្យសិក្សាមានស្តង់ដាអប្បបរមា និងទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ។

រូបមន្តគណនាទូទៅ៖

$$\text{លទ្ធផលសម្រេចជាភាគរយ} = \frac{\text{ចំនួនសូចនាករដែលអនុវត្តបាន}}{\text{ចំនួនសូចនាករសរុប}} \times ១០០$$

## ៨. បែបបទនិងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ

### ៨.១ គោលការណ៍ទូទៅ និងលក្ខណៈវិនិច្ឆ័យ

ការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ផ្អែកលើវឌ្ឍនភាពនៃសាលាមត្តេយ្យសិក្សា និងត្រូវធ្វើនៅរៀងរាល់ឆ្នាំសិក្សានីមួយៗ។ លក្ខណៈវិនិច្ឆ័យ និងឧបករណ៍ស្វ័យវាយតម្លៃសាលាមត្តេយ្យសិក្សាដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូជាឧបសម្ព័ន្ធនៃឯកសារនេះ។

ការទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

### ៨.២ យន្តការ បែបបទ និងនីតិវិធី

#### ៨.២.១ សាលាមត្តេយ្យសិក្សា

នាយកសាលាមត្តេយ្យសិក្សាត្រូវសហការជាមួយគណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាធ្វើស្វ័យវាយតម្លៃ ឱ្យបានច្បាស់លាស់មុននឹងដាក់ពាក្យស្នើសុំការវាយតម្លៃតាមឋានានុក្រមដើម្បីទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ។

នាយកសាលាមត្តេយ្យសិក្សាត្រូវដាក់ពាក្យស្នើសុំជូនអភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីសុំការវាយតម្លៃទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ។ សំណុំបែបបទសម្រាប់ដាក់ពាក្យស្នើសុំត្រូវមាន៖

- ពាក្យស្នើសុំវាយតម្លៃទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ..................០៣ច្បាប់
- របាយការណ៍ស្វ័យវាយតម្លៃ ...................................................................០៣ច្បាប់
- បញ្ជីវត្តមានប្រជុំស្វ័យវាយតម្លៃ ...............................................................០៣ច្បាប់
- ដីការសម្រេចទទួលស្គាល់គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សា..............០៣ច្បាប់
- រូបថតសន្លឹក ឬ រូបថតវីដេអូ នៃទីតាំង ទីធ្លា ថ្នាក់រៀន និងសកម្មភាពពាក់ព័ន្ធ

#### ៨.២.២ រដ្ឋបាលក្រុង ស្រុក ខណ្ឌ

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតគណៈកម្មការវាយតម្លៃសាលាមត្តេយ្យសិក្សាដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពដូចខាងក្រោម៖

- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ប្រធាន
- អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ អនុប្រធាន
- នាយករដ្ឋបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សមាជិកអចិន្ត្រៃយ៍
- មន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូចនៃការិយាល័យអប់រំ យុវជន និងកីឡា សមាជិក

សមាសភាពជាក់ស្តែងនៃគណៈកម្មការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

គណៈកម្មការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូថ្នាក់ក្រុង ស្រុក ខណ្ឌ មានភារកិច្ចប្រជុំវាយតម្លៃ និងចុះពិនិត្យផ្ទាល់ដល់ទីតាំងសាលាមត្តេយ្យសិក្សាដោយផ្ទៀងផ្ទាត់របាយការណ៍ស្វ័យវាយតម្លៃ លក្ខណវិនិច្ឆ័យនៃការវាយតម្លៃសាលាមត្តេយ្យសិក្សា និងស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ។ បន្ទាប់ពីបានវាយតម្លៃរួច អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍វាយតម្លៃបញ្ជូនមកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដោយភ្ជាប់ឯកសារពាក់ព័ន្ធរួមមាន៖

- ពាក្យស្នើសុំវាយតម្លៃទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ..................០៣ច្បាប់
- តារាងលទ្ធផលតាមចំណាត់ថ្នាក់នៃការវាយតម្លៃរបស់គណៈកម្មការ..................០៣ច្បាប់
- ដីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃថ្នាក់ក្រុង ស្រុក ខណ្ឌ ............០៣ច្បាប់
- របាយការណ៍ប្រជុំវាយតម្លៃ..........................................................................០៣ច្បាប់
- បញ្ជីវត្តមានប្រជុំវាយតម្លៃ..........................................................................០៣ច្បាប់
- របាយការណ៍ស្វ័យវាយតម្លៃពីសាលាមត្តេយ្យសិក្សា ......................................០៣ច្បាប់

### ៨.២.៣ មន្ទីរអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូថ្នាក់រាជធានី ខេត្ត ដែលមានសមាសភាពដូចខាងក្រោម៖

- ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធាន
- អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា សមាជិក
- ប្រធានការិយាល័យអប់រំកុមារតូច សមាជិកអចិន្ត្រៃយ៍
- ប្រធាន/តំណាងការិយាល័យបុគ្គលិក សមាជិក
- ប្រធាន/តំណាងការិយាល័យគណនេយ្យ សមាជិក
- ប្រធាន/តំណាងការិយាល័យអធិការកិច្ច សមាជិក
- អនុប្រធានការិយាល័យអប់រំកុមារតូច សមាជិក

សមាសភាពជាក់ស្តែង នៃគណៈកម្មការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយលិខិតបង្គាប់ការឬលិខិតឧទ្ទេសនាមរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡា។

គណៈកម្មការវាយតម្លៃសាលាមត្តេយ្យសិក្សាដើម្បីផ្តល់ការទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូថ្នាក់រាជធានី ខេត្ត មានភារកិច្ចប្រជុំពិនិត្យលើលទ្ធផលនៃការវាយតម្លៃរបស់អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយផ្ទៀងផ្ទាត់របាយការណ៍ស្វ័យវាយតម្លៃ លក្ខណវិនិច្ឆ័យនៃការវាយតម្លៃស្តង់ដា

សាលាមត្តេយ្យសិក្សាគំរូ និងចុះពិនិត្យផ្ទាល់ដល់ទីតាំងជាក់ស្តែងក្នុងករណីចាំបាច់។ បន្ទាប់ពីបានវាយតម្លៃរួច ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបការវាយតម្លៃបញ្ជូនមកក្រសួងអប់រំ យុវជន និងកីឡា ដោយភ្ជាប់ឯកសារពាក់ព័ន្ធរួមមាន៖

- ពាក្យស្នើសុំវាយតម្លៃទទួលស្គាល់ជាស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ..................០៣ច្បាប់
- តារាងលទ្ធផលតាមចំណាត់ថ្នាក់នៃការវាយតម្លៃរបស់គណៈកម្មការ ..................០៣ច្បាប់
- លិខិតបង្គាប់ការឬលិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃថ្នាក់រាជធានី ខេត្ត.....០៣ច្បាប់
- របាយការណ៍ប្រជុំវាយតម្លៃ............................................................................០៣ច្បាប់
- បញ្ជីវត្តមានប្រជុំវាយតម្លៃ ............................................................................០៣ច្បាប់
- សំណុំឯកសារវាយតម្លៃរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌ..........................០៣ច្បាប់
- របាយការណ៍ស្វ័យវាយតម្លៃពីសាលាមត្តេយ្យសិក្សា ......................................០៣ច្បាប់

### ៨.២.៤ ក្រសួងអប់រំ យុវជន និងកីឡា

សមាសភាពជាក់ស្តែង និងតួនាទីភារកិច្ចរបស់គណៈកម្មការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ កំណត់ដោយសេចក្តីសម្រេចដោយឡែករបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៩. សេចក្តីសន្និដ្ឋាន

ស្តង់ដាសាលាមត្តេយ្យសិក្សាគំរូជាឧបករណ៍សម្រាប់វាយតម្លៃដែលគ្រប់ភាគីពាក់ព័ន្ធ ដូចជារដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យ អប់រំ យុវជន និងកីឡាជាសេនាធិការ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា អាចយកទៅប្រើប្រាស់ក្នុងការវាយតម្លៃ ស្របតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើ លទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច ឬប្រព័ន្ធផ្សេងទៀត ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍសាលាមត្តេយ្យសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថាគ្រប់សាលាមត្តេយ្យសិក្សាទូទាំងប្រទេស នឹងខិតខំអភិវឌ្ឍន៍ខ្លួនឱ្យស្របតាមស្តង់ដាសាលាមត្តេយ្យសិក្សាគំរូនេះ ដើម្បីពង្រឹងស័ក្តិសិទ្ធភាពនៃការអភិវឌ្ឍស្ថាប័ន ប្រកបដោយចីរភាពឆ្ពោះទៅការលើកកម្ពស់គុណភាពការអប់រំកុមារតូច ធានាបាននូវប្រសិទ្ធភាពនៃលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរឡើងអនាគតប្រែក្លាយជាពលរដ្ឋល្អ មានគុណសម្បទាពលរដ្ឋសកល សម្រាប់កសាងសង្គមសន្តិភាពនៃជាតិកម្ពុជាជានិរន្តន៍។

**ឧបសម្ព័ន្ធ**
**ស្តីពី**
**បែបបទនិងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ**

## I. ព័ត៌មានទូទៅ

១. រាជធានី ខេត្ត ៖...............................................................
២. ក្រុង ស្រុក ខណ្ឌ ៖...............................................................
៣. ឃុំ សង្កាត់ ៖...............................................................
៤. សាលាមត្តេយ្យសិក្សា ៖...............................................................
៥. លេខកូដសាលារៀន ៖...............................................................
៥. ឈ្មោះនាយក ៖...............................................................
៦. លេខទូរស័ព្ទនាយក ៖...............................................................
៦. ថ្ងៃខែឆ្នាំពិនិត្យនិងវាយតម្លៃ ៖...............................................................
៧. អ្នកត្រួតពិនិត្យ និងវាយតម្លៃ ៖...............................................................
៨. លេខទូរស័ព្ទអ្នកត្រួតពិនិត្យ ៖...............................................................

## II. នីតិវិធីនៃការវាយតម្លៃសាលាមត្តេយ្យសិក្សាគំរូ

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស | | | | | | | |
| ១ | ការប្រមូលកុមារចូលរៀន | | | | | | |
| ១.១ | ភាគរយនៃការចូលរៀនរបស់កុមារអាយុ ៥ឆ្នាំ | - ចំនួនកុមារអាយុ៣, ៤, និង ៥ឆ្នាំ ធៀបនឹងចំនួនកុមារ(ស្ថិតិប្រជាជនអាយុ ៣, ៤, និង៥ ឆ្នាំ)<br>- សាលារៀនមានស្ថិតិកុមារអាយុ ៣, ៤ និង៥ឆ្នាំ ចូលរៀន នៅដើមឆ្នាំសិក្សា (ភូមិចំណុះសាលារៀន)<br>- ផែនទី និងទិន្នន័យខ្នងផ្ទះ<br>- សំបុត្រកំណើត និងសៀវភៅគ្រួសារ<br>- តារាង/បញ្ជីឈ្មោះសិស្សតាមគ្រួសារ(ភូមិចំណុះសាលារៀន | ៦៥% | ៧០% | ៧៥% | ៨០% | ៨៥% |
| ១.២ | ភាគរយនៃការចូលរៀនរបស់កុមារអាយុ ៤ឆ្នាំ | | ៤០% | ៤៥% | ៥០% | ៥៥% | ៦០% |
| ១.៣ | ភាគរយនៃការចូលរៀនរបស់កុមារអាយុ ៣ឆ្នាំ | | ២០% | ២៥% | ៣០% | ៣៥% | ៤០% |
| ២ | កុមាររៀនបានគង់វង្សនៅក្នុងសាលារៀន | | | | | | |
| ២.១ | ភាគរយកុមារអាយុ ៥ឆ្នាំ បានឆ្លងកាត់មត្តេយ្យ សិក្សា និងទៅចូលរៀនថ្នាក់ទី១ | - ចំនួនសិស្សអាយុ៦ឆ្នាំដែលបានចូលរៀនថ្នាក់ទី១និងធ្លាប់បានឆ្លងកាត់មត្តេយ្យសិក្សា ធៀបនឹងចំនួនសិស្សថ្នាក់ទី១ | ៧០% | ៧៥% | ៨០% | ៨៥% | ៩០% |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | នៅសាលា បឋមសិក្សា | - សាលារៀនមានស្ថិតិកុមារអាយុ ៥ឆ្នាំ ចូលរៀនថ្នាក់ទី១ សាលាបឋមសិក្សា | | | | | |
| ៣ | **លទ្ធផលនៃការសិក្សារបស់សិស្ស** | | | | | | |
| ៣.១ | ភាគរយកុមារអាយុ៥ឆ្នាំ មានការអភិវឌ្ឍផ្នែកទាំង៥ បានល្អប្រសើរ | - សាលារៀនមានរបាយការណ៍វាយតម្លៃលទ្ធផលនៃការសិក្សាកុមារ៥ឆ្នាំ ប្រចាំឆ្នាំសិក្សា | ៨០% | ៨៥% | ៩០% | ៩៥% | ១០០ % |
| ៤ | **ស្ថានភាពអាហារូបត្ថម្ភរបស់សិស្ស** | | | | | | |
| ៤.១ | ភាគរយកុមារមានស្ថានភាពអាហារូបត្ថម្ភធម្មតា | - បញ្ជីកត់ត្រាស្ថានភាពអាហារូបត្ថម្ភកុមារ (អាយុ ទម្ងន់ កម្ពស់)<br>- សៀវភៅតាមដានសុខភាពសិស្សម្នាក់ៗ | ៧០% | ៧៥% | ៨០% | ៨៥% | ៩០% |
| ៤.២ | ភាគរយកុមារដែលមានបញ្ហាអាហារូបត្ថម្ភទទួលបានកិច្ចអន្តរាគមន៍ | - របាយការណ៍ត្រឡប់ពីមាតាបិតាឬអ្នកអាណាព្យាបាល ក្នុងការសហការជួយអន្តរាគមន៍ឬការនាំកុមារទៅរកសេវាគាំទ្រ<br>- របាយការណ៍ពីកិច្ចអន្តរាគមន៍របស់សេវាសុខាភិបាលមូលដ្ឋានតាមរយៈគណៈកម្មការសុខភាពសិក្សាតាមសាលារៀន | ៧០% | ៧៥% | ៨០% | ៨៥% | ៩០% |
| ៤.៣ | ភាគរយកុមារក្រីក្រទទួលបានការឧបត្ថម្ភនានា | - របាយការណ៍ស្តីពីការផ្តល់ការឧបត្ថម្ភនានារបស់កម្មវិធីជាតិ ឬកម្មវិធីគាំទ្ររបស់ដៃគូអភិវឌ្ឍ | ៧០% | ៧៥% | ៨០% | ៨៥% | ៩០% |
| ៥ | **សីលធម៌ និងឥរិយាបថរបស់សិស្ស** | | | | | | |
| ៥.១ | ភាគរយកុមារទទួលកិច្ចគាំពារនិងប្រឹក្សាយោលបល់ | - សាលារៀនមានបញ្ជី ព័ត៌មានកត់ត្រាចំនួនកុមារ រងហិង្សា(ដូចជាហិង្សាផ្លូវកាយ, ហិង្សាផ្លូវចិត្ត, ហិង្សាផ្លូវភេទ និងការមិនអើពើ) សាលារៀនមានផែនការប្រឹក្សាយោបល់ជាមួយមាតាបិតា អ្នកអាណាព្យាបាល<br>- របាយការណ៍ទទួលបានពីក្រុមបណ្តាញឪពុកម្តាយ និងគ.ក.ន.ក.<br>- សាលារៀនមានរបាយការណ៍ និងបញ្ជីវត្តមានការប្រឹក្សាយោបល់ជាមួយមាតាបិតា អ្នកអាណាព្យាបាល | ៨០% | ៨៥% | ៩០% | ៩៥% | ១០០ % |
| ៥.២ | ភាគរយថ្នាក់រៀនបានអនុវត្តកម្មវិធីទម្លាប់ល្អ(សីលធម៌ និងឥរិយាបថកុមារ)ជាប្រចាំ | - របាយការណ៍ និងការចុះពិនិត្យវាយតម្លៃ<br>- ផ្ទៀងផ្ទាត់ជាមួយបញ្ជីលទ្ធផលសៀវភៅតាមដានការសិក្សា | ៧០% | ៧៥% | ៨០% | ៨៥% | ៩០% |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| ស្តង់ដាទី២៖ ការបង្រៀន និងរៀន | | | | | | | |
| ១ | **ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី** | | | | | | |
| ១.១ | ភាគរយថ្នាក់រៀនបានអនុវត្តវិធីសាស្ត្ររៀនតាមរយៈការលេង (Learning Throught Play) | - សាលារៀនមានផែនការសកម្មភាពលេងតាមប្រធានបទ<br>- សាលារៀនមានតារាងរបាយម៉ោងសិក្សាអនុវត្តការលេងដោយសេរី ការលេងដោយមានការណែនាំ និងការលេង ល្បែងសិក្សាតាមកម្មវិធីសិក្សាពេញលេញ<br>- សាលារៀនមានបញ្ជីសម្ភារៈល្បែងសិក្សា<br>- សាលារៀនមានសម្ភារៈល្បែងសិក្សារៀបចំតាមជ្រុងថ្នាក់ រៀន<br>- សាលារៀនមានឯកសារសកម្មភាពរបស់កុមារម្នាក់ៗ (Portfolio) | ២០% | ៤០% | ៦០% | ៨០% | ១០០% |
| ១.២ | ភាគរយថ្នាក់រៀនបានប្រើប្រាស់បច្ចេកវិទ្យា សម្រាប់ការបង្រៀននិងរៀន | - សាលារៀនមានបន្ទប់កុំព្យូទ័រ និងបណ្ណាល័យ<br>- បន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Boad) | ២០% | ៤០% | ៦០% | ៨០% | ១០០% |
| ២ | **ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន** | | | | | | |
| ២.១ | សាលារៀនបានរៀបចំបំណែងចែកកម្មវិធីសិក្សាតាមកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា | - សាលារៀនមានតារាងបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែ ប្រចាំសប្តាហ៍ និងតាមមុខវិជ្ជា<br>- សាលារៀនមានផែនការបង្រៀនប្រចាំថ្ងៃ តាមកាលវិភាគ ប្រចាំសប្តាហ៍ ផែនការបង្រៀន ៣ខែម្តងៗ | ≤ ៨០% | > ៨០% | > ៩០% | > ៩៥% | ១០០% |
| ២.២ | ភាគរយថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា | - សាលារៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមកម្រិតថ្នាក់ និងតាមមុខវិជ្ជា | <៧០% | ៨៥% | ៩០% | ៩៥% | ១០០% |
| ២.៣ | ភាគរយគ្រូបង្រៀនបានធ្វើបច្ចុប្បន្នកម្មកិច្ចតែងការបង្រៀនត្រឹមត្រូវ និងបានអនុវត្តទៀងទាត់ | - គ្រូបង្រៀនបានរៀបចំកិច្ចតែងការបង្រៀនប្រចាំថ្ងៃ តាម កម្រិតថ្នាក់ និងចុះទិដ្ឋាការមុននឹងបង្រៀន ដោយនាយក សាលា<br>- សាលារៀនមានស្វ័យវាយតម្លៃលើការអនុវត្តកិច្ចតែងការបង្រៀន | ≤ ៥០% | > ៥០% | > ៧០% | > ៨៥% | ≤ ៩៥% |
| ២.៤ | សាលារៀនបានប្រជុំវាយតម្លៃការអនុវត្តកម្មវិធីសិក្សា | - សាលារៀនមានផែនការប្រជុំប្រចាំខែ ឆ្នាំ<br>- សាលារៀនមានរបាយការណ៍ឬ | ៣ | ៥ | ៧ | ៩ | ១០ |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | ករណីធៀបផ្ទាត់សូចនាករ | កម្រិតធៀបផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | ប្រចាំឆមាស និងប្រចាំឆ្នាំ | កំណត់ហេតុប្រជុំ<br>- សាលារៀនមានរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីសិក្សាប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ | | | | | |
| ២.៥ | ភាគរយថ្នាក់រៀនបិទទ្វារ (សរុបថ្នាក់ទាំងអស់គិតជាមធ្យម) | - របាយការណ៍បូកសរុបបញ្ជីគ្រប់គ្រងវត្តមានរបស់សាលារៀន<br>- បញ្ជីវត្តមានប្រចាំថ្ងៃ<br>- ការបញ្ជាក់ពីប្រភពផ្សេងៗទៀត | ១០% | ៧% | ៥% | ៣% | ០% |
| ២.៦ | ចំនួនថ្ងៃសាលារៀនបិទទ្វារដោយមិនមានការអនុញ្ញាត | - សាលារៀនមានកំណត់ហេតុពីការផ្អាកដំណើរការបង្រៀននិងរៀន | ៤ | ៣ | ២ | ១ | ០ |
| ៣ | សម្ភារៈរៀន និងបង្រៀន | | | | | | |
| ៣.១ | ភាគរយថ្នាក់រៀនមានសម្ភារៈបង្រៀន និងរៀនគ្រប់គ្រាន់តាមកម្មវិធីសិក្សា និងបានឱ្យកុមារមានសម្ភារៈសម្រាប់លេងបានគ្រប់គ្រាន់ | - សាលារៀនមានសម្ភារៈសម្រាប់កុមារលេងតាមកម្មវិធីសិក្សា<br>- សាលារៀន/ថ្នាក់រៀនមានសម្ភារៈផលិតដោយគ្រូ និងកុមារ<br>- សាលារៀនមានបញ្ជីស្រង់ឈ្មោះសម្ភារៈដែលបានផលិត<br>- សាលារៀនមានសម្ភារៈលេងមានចំនួនគ្រប់គ្រាន់សម្រាប់ កុមារយ៉ាងតិច៩៥%<br>- សាលារៀនមានការរៀបចំជ្រុងថ្នាក់រៀនត្រឹមត្រូវតាម ប្រកាសលេខ ១៤៥៤ អយក.ប្រក ចុះថ្ងៃទី១០ សីហា ២០២២<br>- សាលារៀនមានបញ្ជីកត់ត្រាសម្ភារៈ | <៧០% | ៨៥% | ៩០% | ៩៥% | ១០០% |
| ៤ | **ការជួយគាំទ្រសិស្ស** | | | | | | |
| ៤.១ | ភាគរយកុមារបានធ្វើកិច្ចការនៅសាលារៀន និងមានការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀន | - សាលារៀនមានគ្រូកត់ត្រាសកម្មភាពកុមារអនុវត្តប្រចាំថ្ងៃ<br>- សាលារៀនមានសន្លឹកកិច្ចការសម្រាប់កុមារអនុវត្តតាមខ្លឹមសារមេរៀននិងឯកភាពពីមាតាបិតា ឬអ្នកអាណាព្យាបាល | ៧៥% | ៨០% | ៨៥% | ៩០% | ៩៥% |
| ៤.២ | ភាគរយកុមារបានធ្វើកិច្ចការនៅផ្ទះ និងមាន ការផ្តល់មូលវិចារណ៍ល្អពីគ្រូបង្រៀន | | ៧៥% | ៨០% | ៨៥% | ៩០% | ៩៥% |
| ៥ | **ដំណើរការបណ្ណាល័យ** | | | | | | |
| ៥.១ | សាលាបានរៀបចំបណ្ណាល័យត្រឹមត្រូវ និងដំណើរការជា | - សាលារៀនមានបណ្ណាល័យ ដែលកុមារអាចអនុវត្តសកម្មភាពបាន(បន្ទប់ដាច់ | ១ | ២ | ៣ | ៤ | ៥ |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | ប្រចាំ | ដោយឡែក ឬផ្នែកមួយនៃ ជ្រុងទីចាត់ការ ឬថ្នាក់រៀន)<br>- សាលារៀនមានដាក់តាំងសៀវភៅច្រើនប្រភេទស្របតាមវ័យកុមារ<br>- សាលារៀនមានចាត់តាំងឱ្យមានបណ្ណារក្សជាប្រចាំ<br>- សាលារៀនមានរៀបចំបញ្ជីរួម បញ្ជីសារពើភណ្ឌ បញ្ជីខ្ចី និងបញ្ជីសង<br>- សាលារៀនមានរៀបចំកាលវិភាគចូលបណ្ណាល័យ<br>- សាលារៀនមានបញ្ជីឈ្មោះកុមារចូលបណ្ណាល័យ | | | | | |
| ៦ | **សាលារៀនបានធ្វើអធិការកិច្ចផ្ទៃក្នុង ត្រឹមត្រូវតាមផែនការកំណត់** | | | | | | |
| ៦.១ | ភាគរយថ្នាក់រៀននាយកបានចុះអធិការកិច្ចសង្កេតការបង្រៀន | - សាលារៀនមានផែនការអធិការកិច្ចការបង្រៀននិងការគ្រប់គ្រងថ្នាក់រៀនសម្រាប់ឆ្នាំសិក្សា<br>- នាយកសាលារៀនបានចុះសង្កេតការបង្រៀនឆ្លើយតបតាមផែនការ<br>- សាលារៀនមានរបាយការណ៍អធិការកិច្ចការបង្រៀននិងការគ្រប់គ្រងថ្នាក់រៀនរបស់គ្រូបង្រៀន<br>- សាលារៀនមានគ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យ<br>- សាលារៀនមានគ្រូបង្រៀនទទួលបានការធ្វើអធិការកិច្ចផ្ទៃក្នុងយ៉ាងតិច១ដងក្នុង១ឆ្នាំ | ៧០% | ៨៥% | ៩០% | ៩៥% | ១០០% |
| ៧ | - ការប្រជុំបច្ចកទេស | | | | | | |
| ៧.១ | សាលារៀនបានរៀបចំការប្រជុំបច្ចេកទេសទៀងទាត់តាមផែនការរបស់សាលារៀន | - សាលារៀនមានផែនការការប្រជុំប្រចាំខែឆ្នាំ<br>- សាលារៀនមានរបាយការណ៍/កំណត់ហេតុប្រជុំ និងបញ្ជីវត្តមាន | ១៤ | ២០ | ២៥ | ៣០ | ៣៥ |
| ៨ | **ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា** | | | | | | |
| ៨.១ | ចំនួនដងសាលារៀនបានរៀបចំកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់កុមារអាយុ៥ | - សាលារៀនមានផែនការទស្សនកិច្ចសិក្សារបស់កុមារអាយុ៥ឆ្នាំ<br>- សាលារៀនមានកិច្ចព្រមព្រៀងរវាងសាលា | ១ | ២ | ៣ | ៤ | ៥ |

| លរ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | ឆ្នាំ នៅសាលាបឋមសិក្សា ឬតំបន់ ផ្សេងៗ | មត្តេយ្យ និងសាលាបឋមសិក្សា<br>- សាលារៀនមានរៀបចំបញ្ជីឈ្មោះកុមារអាយុ៥ឆ្នាំ និងមាតាបិតា<br>- សាលារៀនមានប្រជុំផ្សព្វផ្សាយជាមួយមាតាបិតា<br>- សាលារៀនមានរបាយការណ៍ | | | | | |
| ៨.២ | សាលាមានបង្កើតកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់មត្តេយ្យសិក្សា | - សាលារៀនមានផែនការប្រជុំជាមួយមាតាបិតាប្រចាំឆ្នាំ<br>- សាលារៀនមានកំណត់ហេតុប្រជុំ បញ្ជីវត្តមាន<br>- សាលារៀនមានរចនាសម្ព័ន្ធកម្មវិធី<br>- សាលារៀនមានឯកសារម៉ូឌុលអប់រំមាតាបិតា | ១ | ២ | ៣ | ៤ | ៥ |
| ៨.៣ | សាលាមានកម្មវិធីប្រឹក្សាគរុកោសល្យជាមួយគ្រូសាលាមត្តេយ្យសិក្សា/មត្តេយ្យសិក្សាឯកជន/ថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា | - សាលារៀនមានរចនាសម្ព័ន្ធបណ្តាញសាលាក្នុងសហគមន៍<br>- សាលារៀនមានផែនការប្រចាំឆ្នាំការជួយសាលារៀនក្នុងបណ្តាញ<br>- សាលារៀនមានកិច្ចព្រមព្រៀងជាមួយសាលារៀន<br>- សាលារៀនមានកំណត់ហេតុប្រជុំ បញ្ជីវត្តមាន | ១ | ២ | ៣ | ៤ | ៥ |
| ៨.៤ | សាលារៀនមានរៀបចំព្រឹត្តិការណ៍បង្ហាញទេពកោសល្យកុមារ និងមាតាបិតា | - សាលារៀនមានផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំ<br>- សាលារៀនមានរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ | ១ | ២ | ៣ | ៤ | ៥ |
| **៩** | **ការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌** | | | | | | |
| ៩.១ | សាលារៀនបានអនុវត្តកម្មវិធីការអប់រំសីលធម៌ និងចរិយាធម៌(ការអប់រំកុមារពីរបៀបនៃការ សំពះ ការគួរសម ការអប់រំឥរិយាបទដេក ដើរ ឈរ អង្គុយ និងការប្រើពាក្យសំដី) | - សាលារៀនមានអនុវត្តការអប់រំចិត្តសង្គមកុមារ<br>- សាលារៀនមានកម្មវិធីអប់រំផ្លូវចិត្តមាតាបិតា អ្នកអាណាព្យាបាល<br>- សាលារៀនមានរៀបចំកម្មវិធីអប់រំបែបពុទ្ធសាសនា<br>- សៀវភៅតាមដានការសិក្សាមានការផ្តល់មូលវាចារលើការអប់រំចរិយាធម៌កុមារ | ១ | ២ | ៣ | ៤ | ៥ |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតធៀបផ្ទាត់សូចនាករ | កម្រិតធៀបផ្ទាត់លទ្ធផល (ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | | - របាយការណ៍ស្តីពីការអនុវត្ត និងការពិនិត្យតាមដាន និងជំរុញការអនុវត្ត | | | | | |
| ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍ | | | | | | | |
| ១ | ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន | | | | | | |
| ១.១ | ចំនួនដងគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស.) ប្រជុំក្នុងមួយឆ្នាំ | - សាលារៀនមានរបាយការណ៍ប្រជុំស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន<br>- លិខិតបង្គាប់ការគណៈកម្មការគ្រប់គ្រងសាលារៀនមានការទទួលស្គាល់តាមការណែនាំ<br>- រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចច្បាស់លាស់តាមការណែនាំ<br>- របាយការណ៍ប្រជុំ និងរបាយការណ៍វឌ្ឍនភាពតាមការណែនាំ<br>- របាយការណ៍បង្ហាញអំពីការគាំទ្រឱ្យសាលារៀនមានការអភិវឌ្ឍទាំងលទ្ធផលសិក្សារបស់កុមារ និងការកែលម្អបរិស្ថានសាលារៀន | ៣ | ៥ | ៧ | ៩ | ១០ |
| ២ | ការចូលរួមរបស់សហគមន៍ | | | | | | |
| ២.១ | ភាគរយមាតាបិតា អ្នកអាណាព្យាបាលចូលរួមប្រជុំតាមការអញ្ជើញរបស់នាយកសាលា | - សហគមន៍បានចូលរួមប្រជុំទៀងទាត់តាមផែនការ<br>- សហគមន៍ចូលរួមរៀបចំបរិស្ថានបៃតង អនាម័យ អគារសិក្សា បន្ទប់រៀន សង្ហារិម និងបរិក្ខារសិក្សាបាន ថែរក្សា និងពង្រីកបន្ថែមតាមបែបបច្ចេកវិទ្យា | ៧៥% | ៨០% | ៨៥% | ៩០% | ៩៥% |
| ២.២ | សាលារៀនមានសកម្មភាពកិច្ចសហការបច្ចេកទេសជាមួយភាពជាដៃគូវិនិយោគរវាងវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍលើការរៀបចំអាហារសម្រន់ ឬអាហារតាមសាលារៀន, កន្លែងក្មេងលេង | - សាលារៀនមានកិច្ចព្រមព្រៀងជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ | ១ | ២ | ៣ | ៤ | ៥ |
| ៣ | ការគាំទ្ររបស់សហគមន៍ | | | | | | |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល (ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| ៣.១ | សហគមន៍បានចូលរួមជួយគាំទ្រ មូលនិធិដំណើរការសាលារៀន និងសកម្មភាពរបស់សាលារៀន | - សាលារៀនមានបញ្ជីរបាយការណ៍ចំណូលចំណាយថវិកា<br>- សាលារៀនមានបញ្ជីរបាយការណ៍សម្ភារៈ<br>- សាលារៀនកត់ត្រាសកម្មភាពរបស់សហគមន៍ចូលរួមជួយរៀបចំអានាម័យ និងការថែទាំបរិស្ថាន<br>- សាលារៀនកត់ត្រាសកម្មភាពរបស់សហគមន៍ចូលរួមជួយរៀបចំសន្តិសុខ និងសណ្តាប់សាលារៀន<br>- របាយការណ៍បូកសរុបការគាំទ្ររបស់សហគមន៍ប្រចាំ | ១ | ២ | ៣ | ៤ | ៥ |
| ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន | | | | | | | |
| ១ | ការគ្រប់គ្រងទូទៅ និងរដ្ឋបាល | | | | | | |
| ១.១ | សាលារៀនបានរៀបចំការគ្រប់គ្រងទូទៅ និងរដ្ឋបាលបានល្អប្រសើរ | - សាលារៀនមានរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងត្រឹមត្រូវ<br>- សាលារៀនមានរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសាលារៀន<br>- សាលារៀនមានបចំណែងចែកតួនាទីភារកិច្ចបុគ្គលិក<br>- សាលារៀនមានស្ថិតិបុគ្គលិកអប់រំ និងកុមារ<br>- បញ្ជីសម្ភារៈ និងសារពើភ័ណ្ឌ | ១ | ២ | ៣ | ៤ | ៥ |
| ១.២ | សាលារៀនប្រើប្រាស់ App សម្រាប់គ្រប់គ្រងទិន្នន័យសាលារៀន | - សាលារៀនប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)<br>- សាលារៀនមានAppសម្រាប់គ្រប់គ្រងទិន្នន័យរបស់សាលារៀន<br>- សាលារៀនមានអ្នកគ្រប់គ្រងទិន្នន័យនិងអាចទាញយកជារបាយការណ៍តាមតម្រូវការ<br>- នាយកសាលាធានាសុចរិតភាពនៃទិន្នន័យដែលបានបញ្ចូលទៅក្នុងប្រព័ន្ធ ឬ App<br>- ទិន្នន័យរបស់សាលារៀនត្រូវបានផ្សព្វផ្សាយដល់សាធារណៈជន ជាពិសេសមាតាបិតា អ្នកអាណាព្យាបាល | ១ | ២ | ៣ | ៤ | ៥ |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | | សហគមន៍ និងអាជ្ញាធរដែនដី | | | | | |
| ១.៣ | ចំនួនគ្រូបង្រៀនខ្វះត្រូវបានដោះស្រាយ | - សាលារៀនមានបញ្ជីគណៈគ្រប់គ្រងនិងគ្រូបង្រៀនលើស ឬខ្វះ | ៤ | ៣ | ២ | ១ | ០ |
| ១.៤ | សាលារៀនមានកម្មវិធីប្រជុំប្រចាំខែ ត្រីមាស និងឆមាសត្រឹមត្រូវ | - សាលារៀនមានផែនការសកម្មភាពការងារ<br>- សាលារៀនមានកម្មវិធីប្រជុំប្រចាំខែ ត្រីមាស និងឆមាស | ៣ | ៥ | ៧ | ៩ | ១០ |
| ២.៥ | សាលារៀនបានរៀបចំរបាយការណ៍ត្រឹមត្រូវតាមការណែនាំ | - សាលារៀនមានរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស<br>- របាយការណ៍សកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ | ប្រចាំខែ | ត្រីមាស | ឆមាស | ប្រចាំឆ្នាំ | សមិទ្ធកម្មប្រចាំឆ្នាំ |
| **២** | **ការរៀបចំផែនការអភិវឌ្ឍសាលារៀន** | | | | | | |
| ២.១ | សាលារៀនបានរៀបចំផែនការត្រឹមត្រូវ | - សាលារៀនមានចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ និង សកម្មភាពគន្លឹះ<br>- សាលារៀនមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ៥ឆ្នាំ<br>- ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ<br>- ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការថវិកាប្រចាំឆ្នាំ<br>- សាលារៀនមានផែនការកែលម្អសាលារៀនបានអនុម័តជាផ្លូវការ | មាន១ | មាន ២ | មាន ៣ | មាន៤ | មាន៤ និង អនុវត្តបាន ចាប់ពី ៩០% ឡើងទៅ |
| **៣** | **ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក** | | | | | | |
| ៣.១ | ភាគរយគ្រូបង្រៀន និងបុគ្គលិកអប់រំបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ | - សាលាបានរៀបចំប្រជុំផ្សព្វផ្សាយអំពីគោលការណ៍នៃការចុះកិច្ចព្រមព្រៀងរវាងនាយកសាលានិងគ្រូបង្រៀន ក្រោមការអនុម័តពីប្រធាន គ.គ.ស.<br>- កិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំរវាងនាយកសាលារៀន និងគ្រូបង្រៀន និងបុគ្គលិកអប់រំ<br>- កិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំរវាងគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈគ្រប់គ្រង<br>- សាលារៀនមានប្រព័ន្ធវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀនប្រចាំឆ្នាំ<br>- សាលារៀនមានកម្មវិធីលើកទឹកចិត្ត(ការ | ≤ ៥០% | > ៥០% | > ៧០% | > ៩០% | ១០០ % |
| ៣.២ | ចំនួននាយកសាលានិងនាយករងបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ | | ១ | ២ | ៣ | ៤ | ទាំងអស់ |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | | លើកសរសើរទស្សនកិច្ចសិក្សាសម្រាប់គ្រូទៅសាលាផ្សេងក្នុងឆ្នាំសិក្សា) | | | | | |
| ៤ | **វាយតម្លៃលទ្ធផលសិក្សា** | | | | | | |
| ៤.១ | ភាគរយថ្នាក់រៀនបានអនុវត្តការវាយតម្លៃលទ្ធផលសិក្សារបស់កុមារតាមកម្មវិធីសិក្សាត្រឹមត្រូវ | - សាលារៀនបានរៀបចំរបៀបរបបវាយតម្លៃលទ្ធផលសិក្សាកុមារតាមកម្មវិធីសិក្សា<br>- សាលារៀនមានផែនការជួយសិស្សអភិវឌ្ឍយឺត<br>- សាលារៀនមានបញ្ជីវាយតម្លៃការអភិវឌ្ឍសមត្ថភាពកុមារ តាមកម្រិតថ្នាក់<br>- សាលារៀនបានអនុវត្តការវាយតម្លៃកុមារ<br>- សាលារៀនមានបញ្ជីលទ្ធផលនៃការវាយតម្លៃការអភិវឌ្ឍ សមត្ថភាពកុមារ | ៨០% | ៨៥% | ៩០% | ៩៩% | ១០០% |
| ៥ | **ការលើកកម្ពស់សុខភាពសិក្សា និងអាហារូបត្ថម្ភ** | | | | | | |
| ៥.១ | ការលើកកម្ពស់សេវាថែទាំសុខភាពបឋម | - គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា មានសមាសភាព តួនាទីភារកិច្ចច្បាស់លាស់ និងមាននីត្យានុកូល<br>- កស្តុតាងនៃបរិក្ខារនិងសម្ភារៈសង្គ្រោះបឋម<br>- របាយការណ៍ស្តីពីការផ្តល់ថ្នាំបង្ការតាមកម្មវិធីជាតិផ្តល់ថ្នាំបង្ការឬថ្នាំទម្លាក់ដង្កូវព្រូន<br>- បន្ទប់សុខភាពនិងសម្ភារៈប្រើប្រាស់ជាមូលដ្ឋានចាំបាច់<br>- យន្តការគ្រប់គ្រងកិច្ចដំណើរការបន្ទប់សុខភាព | ១ | ២ | ៣ | ៤ | ៥ |
| ៥.២ | សាលារៀនបានរៀបចំកម្មវិធីពិនិត្យសុខភាពកុមារ | - ផែនការពិនិត្យសុខភាពកុមារ<br>- សៀវភៅតាមដានសុខភាពកុមារ<br>- របាយការណ៍ទិន្នន័យស្តីពីការពិនិត្យសុខភាពកុមារឬការផ្តល់សេវាសុខភាពផ្សេងៗ<br>- របាយការណ៍ស្តីពីកិច្ចអន្តរាគមន៍ចំពោះសិស្សដែលមានបញ្ហាសុខភាពមិនល្អបានទៅទទួលសេវាគាំទ្រ | ១ | ២ | ៣ | ៤ | ៥ |
| ៥.៣ | ការលើកកម្ពស់ទឹកស្អាត និងអនាម័យ | - បង្គន់អនាម័យ កន្លែងលាងសម្អាតដៃបណ្តាញទឹកស្អាត<br>- កម្មវិធីការគ្រប់គ្រងអនាម័យកុមារ<br>- បណ្តាញទឹកស្អាតសម្រាប់ទទួលទាន | ១ | ២ | ៣ | ៤ | ៥ |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | ករ្រិតផ្លៀងផ្ទាត់សូចនាករ | ករ្រិតផ្លៀងផ្ទាត់លទ្ធផល(ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | | របស់គ្រូ និងកុមារ<br>- កាលវិភាគស្តីពីការលាងសម្អាតដៃនិងដុសសម្អាតធ្មេញជាក្រុមសម្រាប់សិស្សទាំងអស់ | | | | | |
| ៥.៤ | ការលើកកម្ពស់សុវត្ថិភាពចំណីអាហារប្រកបដោយសុខភាព | - ការបិទផ្សាយគោលការណ៍ណែនាំស្តីពីការលើកកម្ពស់ សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព<br>- អ្នកលក់មានកិច្ចសន្យាច្បាស់លាស់ជាមួយនាយកសាលា ឬអាជ្ញាធរមានសមត្ថកិច្ច<br>- យន្តការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនិងអាហារ ប្រកបដោយសុខភាព | ១ | ២ | ៣ | ៤ | ៥ |
| ៥.៥ | ការអនុវត្តកម្មវិធីអប់រំសុខភាព | - ផែនការបង្រៀននិងកាលវិភាគអប់រំសុខភាព<br>- សៀវភៅតាមដានការអប់រំសុខភាព<br>- របាយការណ៍ពីការអប់រំផ្សព្វផ្សាយពីសារសុខភាពផ្សេងៗគ្រប់រូបភាព<br>- របាយការណ៍លទ្ធផលអប់រំសុខភាព | ១ | ២ | ៣ | ៤ | ៥ |
| ៥.៦ | ការលើកកម្ពស់បរិស្ថានស្អាតបៃតង សុវត្ថិភាព អនាម័យនិងមេត្រីភាព | - ធុងសំរាមបានរៀបចំស្របតាមលក្ខណៈបច្ចេកទេស ឬមានឡដុតសំរាមតាមស្តង់ដាបច្ចេកទេស<br>- សួនផ្កាលម្អរុក្ខជាតិ ដើមឈើ សួនបន្លែ<br>វិលជុំ សួនជីវៈចម្រុះ<br>- យន្តការត្រួតពិនិត្យនិងការសម្អាតអនាម័យ<br>- សាលារៀនគ្មានប្រើប្រាស់ថង់ប្លាស្ទីក | ១ | ២ | ៣ | ៤ | ៥ |
| ៥.៧ | ការរក្សាសន្តិសុខសណ្តាប់ធ្នាប់ ការការពារកុមារ ការបង្ការគ្រោះមហន្តរាយនានា | - សាលារៀនមានរបង ទ្វារចេញចូល<br>- សាលារៀនមានប្រព័ន្ធកិច្ចការពារកុមារការរៀបចំយន្តការសណ្តាប់ធ្នាប់ រក្សាសុវត្ថិភាព ការដាក់ស្លាកសញ្ញាចរាចរណ៍ការបង្ការការលង់ទឹក សម្ភារៈបរិក្ខារ ជូនដំណឹងពីសញ្ញាគ្រោះថ្នាក់ បំពង់ពន្លត់អគ្គីភ័យ | ១ | ២ | ៣ | ៤ | ៥ |
| ៥.៨ | សាលារៀនបានអនុវត្តសកម្មភាពអប់រំកាយនិង | - ទីធ្លាសម្រាប់ធ្វើសកម្មភាពអប់រំកាយនិងកីឡា | ២ | ៤ | ៦ | ៨ | ១០ |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល (ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | កីឡា | - តារាងវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សពីអប់រំកាយនិងកីឡា | | | | | |
| ៦ | **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ** | | | | | | |
| ៦.១ | សាលារៀនមានសួនកុមារ និងសម្ភារៈសម្រាប់កុមារលេងដោយសេរី និងមានសុវត្ថិភាព | សាលារៀនមានសួនកុមារនិងសម្ភារៈសម្រាប់កុមារលេងដោយសេរី និងមានសុវត្ថិភាព៖<br>- របងសុវត្ថិភាព<br>- ស្លាកឈ្មោះ<br>- សម្ភារៈល្បែង<br>- ការប្រើប្រាស់ពណ៌<br>- ការរៀបចំស្លាកសញ្ញាសម្គាល់ | ១ | ២ | ៣ | ៤ | ៥ |
| ៦.២ | ភាគរយថ្នាក់រៀនមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំល្អប្រសើរ | - សាលារៀនមានបណ្តាញអគ្គិសនីបំពាក់អ៊ិនធើណេត<br>- បន្ទប់សុខភាព<br>- អាហារដ្ឋាន និងបង្គន់អនាម័យ<br>- សាលារៀនមានបន្ទប់កុំព្យូទ័រ និងបណ្ណាល័យ<br>- បន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Boad) | ≤ ៥% | >៥% | > ១០% | > ១៥% | > ២០ % |
| ស្តង់ដាទី៨ ៖គណនេយ្យភាពរបស់សាលារៀន | | | | | | | |
| ១ | **វេទិកាសាធារណៈ** | | | | | | |
| ១.១ | សាលារៀនរៀបចំកម្មវិធីជួបជុំជាមួយមាតាបិតា អ្នកអាណាព្យាបាលកុមារ និងសហគមន៍ | - សាលារៀនមានផែនការប្រចាំឆ្នាំ<br>- សាលារៀនមានរបាយការណ៍លទ្ធផល<br>- សាលារៀនមានបញ្ជីវត្តមានអ្នកចូលរួម | ១ឆ្នាំ/ម្តង | ៦ខែ/ម្តង | ៣ខែ/ម្តង | ១ខែ/ម្តង | មានកំណត់ហេតុ ឬរបាយការណ៍ប្រជុំ |
| ២ | **ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ** | | | | | | |
| ២.១ | សាលារៀនបានផ្សព្វផ្សាយព័ត៌មានជាសាធារណៈតាមការណែនាំ | - សាលារៀនមានផែនការសាលារៀន<br>- សាលារៀនមានបិទផ្សាយឯកសារសកម្មភាពឬស្នាដៃកុមារនិងព័ត៌មានផ្សេងៗ<br>- សាលារៀនបានផ្តល់របាយការណ៍លទ្ធផលនៃការអភិវឌ្ឍរបស់កុមារយើតឱ្យមាតាបិតា | ១ ឆ្នាំម្តង | ១ ឆមាស ម្តង | ១ ត្រីមាស ម្តង | ១ ខែម្តង | មានឯកសារតម្កល់ទុក |

| ល.រ | ស្តង់ដា<br>សូចនាករគន្លឹះ/សូចនាកររង | កម្រិតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល (ពិន្ទុ) | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| | | អ្នកអាណាព្យាបាល និងសហគមន៍<br>- សាលារៀនមានសកម្មភាពការងាររបស់សាលារៀន<br>- សាលារៀនមានរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ | | | | | |
| ៣ | ការទទួលបានការគាំទ្រពីថ្នាក់ជាតិ | | | | | | |
| ៣.១ | ចំនួនជងនាយក និងនាយករង បានទទួលការ ហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធីសាលារៀនគំរូ | - សាលារៀនមានបញ្ជីរាយនាមនាយកនាយករងទទួលការហ្វឹកហាត់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងកម្មវិធីសាលារៀនគំរូ<br>- សាលារៀនមានរបាយការណ៍លទ្ធផលនៃការអនុវត្ត | ១ | ២ | ៣ | ៤ | ៥ |
| ៣.២ | សាលារៀនបានទទួលការចុះពិនិត្យតាមដាន និងផ្តល់ការគាំទ្រពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | - សាលារៀនមានគ្រូបង្រៀន ក្រុមបច្ចេកទេសនិងគណៈគ្រប់គ្រងសាលារៀនមានបញ្ជីកត់ត្រាជំនួយបច្ចេកទេសពីថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ<br>- សាលារៀនមានតារាងកត់ត្រាទិន្នន័យព័ត៌មាន និងផ្តល់យោបល់ពីការជួយសម្រាប់សាលារៀន ក្នុងការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនពីថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធ<br>- សាលារៀនមានគ្រូបង្រៀនចូលរៀនវគ្គការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ(វិធីសាស្ត្របង្រៀនការប្រឹក្សាគរុកោសល្យ...) | ១ | ២ | ៣ | ៤ | ៥ |

## III. លទ្ធផលៈ

### ចំណុចខ្លាំង

..............................................................................................................................

..............................................................................................................................

..............................................................................................................................

### ចំណុចខ្វះខាត

..............................................................................................................................

..............................................................................................................................

..............................................................................................................................

**អនុសាសន៍**

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

**សេចក្តីសន្និដ្ឋាន**

............................................................................................................................................ ...

.................................................................................................................................................

.................................................................................................................................................

ថ្ងៃ......................ខែ................ឆ្នាំ......ព.ស. ២៥៦..

..........ថ្ងៃទី.............ខែ............ឆ្នាំ២០.........

**មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ**

បានឃើញ និងយល់ព្រម

**នាយកសាលាមត្តេយ្យសិក្សា**

បានឃើញ និងឯកភាព

**ប្រធានក្រុមត្រួតពិនិត្យ និងវាយតម្លៃ**